# សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម

*កំណត់សំគាល់: ការពិពណ៌នាខ្លីៗក្នុងមាតិកាខាងក្រោមនៃមាត្រាទាំងឡាយនៅក្នុងសេចក្តីព្រាងច្បាប់ គឺមិនមែនជាផ្នែកនៃច្បាប់ទេ ប៉ុន្តែការសរសេរត្រង់នេះដើម្បីណែនាំឲ្យយល់ពីសេចក្តីព្រាងច្បាប់ ។*

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

១. គោលបំណងនៃច្បាប់

២. ច្បាប់កំណត់ពីក្របខណ្ឌសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍ដីកសិកម្ម

៣. ច្បាប់អនុវត្តរាល់ដីកសិកម្មទាំងអស់

៤. ការគ្រប់គ្រងដីកសិកម្មអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម

៥. និយមន័យនៃពាក្យគន្លឹះក្នុងច្បាប់ភ្ជាប់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ

## ជំពូកទី ២

## ស្ថាប័នមានសមត្ថកិច្ច

៦. អគ្គនាយកដ្ឋានកសិកម្ម អនុវត្តការគ្រប់គ្រង និងរដ្ឋបាលដីកសិកម្ម

៧. ភារកិច្ចរបស់អគ្គនាយកដ្ឋានកសិកម្ម

## ជំពូកទី ៣

## ការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព

៨. និរន្តរភាពនៃការប្រើប្រាស់ដីកសិកម្ម

៩. និរន្តរភាពនៃការប្រើប្រាស់ដីកសិកម្មត្រូវស្របទៅតាមគោលនយោបាយកសិកម្មជាតិ និងច្បាប់នេះ

១០. ផែនការគ្រប់គ្រងដីកសិកម្មជាតិ

១១. ការគ្រប់គ្រងដីកសិកម្មដោយមានការចូលរួមពីសហគមន៍

១២. តំបន់អភិរក្សជីវៈចម្រុះកសិកម្ម

១៣. អធិបតេយ្យភាពលើធនធានជីវៈនៅក្នុងឬលើដីកសិកម្ម

## ជំពូកទី ៤

## តំបន់អភិវឌ្ឍន៍កសិកម្ម

១៤. គោលបំណងរបស់តំបន់អភិវឌ្ឍន៍កសិកម្ម

១៥. ការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម

១៦. ការបង្កើតសមាគមកសិករខ្នាតតូច

១៧. ការរៀបចំផែនការអភិវឌ្ឍន៍តំបន់

១៨. ការអនុវត្តផែនការអភិវឌ្ឍន៍តំបន់

## ជំពូកទី ៥
## ការអភិរក្សធនធានដី

១៩. គោលបំណង និងទិសដៅនៃការអភិរក្សធនធានដី

២០. ការអនុវត្តវិធានការអភិរក្សដី

២១. ការរៀបចំផែនការអភិរក្សធនធានដីថ្នាក់ជាតិ

២២. សមាគមថែរក្សាការពារដី

២៣. ការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់ដីកសិកម្ម

២៤. បទប្បញ្ញត្តិ និងការអភិរក្សធនធានដី

២៥. មាតិកានៃបទប្បញ្ញត្តិក្នុងការអភិរក្សធនធានដី

## ជំពូកទី ៦
## ការប្រើប្រាស់ និងគ្រប់គ្រងដីកសិកម្មជាលក្ខណៈប្រពៃណីរបស់សហគមន៍

២៦. លក្ខណៈសំខាន់នៃការធ្វើកសិកម្មពនេចរ

២៧. ការទទួលស្គាល់ និងការគាំទ្រកសិកម្មពនេចរ និងនិន្នាការផ្លាស់ប្តូរ

២៨. ការកំណត់ព្រំប្រទល់រដ្ឋបាលនៃតំបន់មិនមែនព្រៃឈើរបស់កសិកម្មពនេចរ

## ជំពូកទី ៧
## ផលិតកម្មកសិកម្មតាមកិច្ចសន្យា

២៩. គោលបំណងរបស់ជំពូក

៣០. វិសាលភាពរបស់ជំពូក

៣១. ក្រសួងដឹកនាំការងារ

៣២. ក្រសួងដែលត្រូវសហការ

៣៣. ការបង្កើតគណៈកម្មការផលិតកម្មកសិកម្មតាមកិច្ចសន្យា

៣៤. សិទ្ធ និងការតព្វកិច្ចរបស់ភាគីផលិត

៣៥. សិទ្ធ និងការតព្វកិច្ចរបស់ភាគីទិញ

៣៦. ទម្រង់របស់កិច្ចសន្យា

៣៧. កិច្ចព្រមព្រៀងក្នុងការបញ្ចប់ជម្លោះ

## ជំពូកទី ៨

### កិច្ចសន្យាជួលដីកសិកម្ម

៣៨. អត្ថន័យនៃកិច្ចសន្យាជួលដីកសិកម្មសម្រាប់គោលបំណងរបស់ជំពូកនេះ

៣៩. មាតិការនៃកិច្ចសន្យាជួល

៤០. ការជួលបន្ត

៤១. លក្ខ័ណ្ឌសម្រាប់អ្នកជួលគេ

៤២. លក្ខ័ណ្ឌសម្រាប់ម្ចាស់

៤៣. ការល្មើសលក្ខណ្ឌ័ទាំងឡាយរបស់អ្នកជួលពីកិច្ចសន្យា

៤៤. បែបបទនៃការបញ្ឈប់

៤៥. អំណាចតុលាការដើម្បីចេញប្រកាសបញ្ឈប់

៤៦. សិទ្ធរបស់អ្នកជួលនៅពេលដែលម្ចាស់ល្មើសលក្ខណ្ឌ័នៃកិច្ចសន្យាជួល

## ជំពូកទី ៩

### ការបំលែងមកជាឬពីដីកសិកម្ម

៤៧. ដីដែលអនុវត្តសម្រាប់ជំពូកនេះ

៤៨. សំណើសុំការអនុញ្ញាតបំលែងដី

៤៩. គណៈកម្មការបំលែងដីកសិកម្ម

៥០. បញ្ហាដែលគណៈកម្មការត្រូវយកចិត្តទុកដាក់នៅពេលអនុញ្ញាតឱ្យមានការបំលែងដី

៥១. ការផ្តល់ការអនុញ្ញាតដល់ការបំលែងដី

៥២. ការអភិវឌ្ឍដីកសិកម្មដោយគ្មានការអនុញ្ញាតឱ្យមានការបំលែងដី និងការប្រព្រឹត្តខុស

៥៣. អនុក្រិត្យដើម្បីផ្តល់បែបបទការអនុញ្ញាតការបំលែងដី

## ជំពូកទី ១០

### បទល្មើស និងទោសប្បញ្ញត្តិ

៥៤. បទល្មើស

៥៥. ការបំផ្លិចបំផ្លាញ

៥៦. ការចេញលិខិតព្រមាន

## ជំពូកទី ១១

### អវសានប្បញ្ញត្តិ

៥៧. សេវាកម្មនៃការប្រកាសជូនដំណឹង និងឯកសារពាក់ព័ន្ធផ្សេងទៀត

៥៨. សិទ្ធនៃការអនុវត្តភារកិច្ច

៥៩. ការលើកទឹកចិត្តដល់អ្នកអនុវត្តកសិកម្មបានល្អ

៦០. ការបង្កើតនូវអនុក្រិត្យផ្សេងៗ

៦១. បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍

៦២. ច្បាប់នេះប្រកាសជាការប្រញាប់

## ឧប្បសម្ព័ន្ធ

## និយមន័យ

**យើង...**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស-រកម-០១៩៦-១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីដីកសិកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី.... នាសម័យប្រជុំពេញអង្គលើកទី........នីតិកាលទី....... ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី................ នាសម័យប្រជុំពេញអង្គលើកទី....នីតិកាលទី..... ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ:

## សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

គោលបំណងនៃច្បាប់នេះគឺត្រូវ:

១. ធានាឱ្យបាននូវការគ្រប់គ្រងដីកសិកម្មប្រកបដោយនិរន្តរភាព

២. ធ្វើឱ្យមានការកើនឡើងនូវផលិតភាពដីកសិកម្ម និងផលប្រយោជន៍សង្គមនិងសេដ្ឋកិច្ច ដែលបានមកពីការបង្កើនផលិតភាពនេះ

៣. ធានាឱ្យបានដល់ការការពារបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមតិកកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា

៤. កែលំអការអភិរក្សធនធានដី

**មាត្រា២ :**

ច្បាប់នេះមានគោលដៅកំណត់ក្របខណ្ឌគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម សម្រាប់អភិវឌ្ឍនវិស័យកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣:**

ច្បាប់នេះអនុវត្តទៅលើដីកសិកម្មទាំងអស់ ទាំងដីរដ្ឋ និងដីឯកជន នៅគ្រប់តំបន់កេរ្សគ្របរិស្ថាននៅក្នុងប្រទេសកម្ពុជា ។ រដ្ឋត្រូវធានាដល់សិទ្ធប្រើប្រាស់ជាលក្ខណៈប្រពៃណីទៅលើដីកសិកម្មសម្រាប់សហគមន៍ ដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ទាំងអស់ដែលកំពុងប្រើប្រាស់ ។

**មាត្រា៤:**

ការគ្រប់គ្រងវិស័យកសិកម្មគឺជាផ្លូវច្បាប់ស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុវត្តផ្ទាល់ដោយអគ្គនាយកដ្ឋានកសិកម្ម ។

ច្បាប់នេះត្រូវអនុវត្ត ក្នុងន័យធានាឱ្យមានការចូលរួមពីសាធារណជនទាំងអស់ ក្នុងរាល់ការសម្រេចចិត្តរបស់រដ្ឋាភិបាល ដែលមានផលប៉ះពាល់ជាសំខាន់ទៅលើជីវភាពរស់នៅរបស់សហគមន៍ ដែលរស់នៅលើ និងប្រើប្រាស់ដីកសិកម្មរបស់ព្រះរាជាណាចក្រកម្ពុជា ។

រាល់សកម្មភាពកសិកម្មសំខាន់ៗទាំងឡាយ នៅគ្រប់តំបន់អេកូឡូស៊ីហើយដែលអាចជះឥទ្ធិពលជាអវិជ្ជមានទៅលើ បរិស្ថាន និងសង្គម ត្រូវធ្វើការវាយតម្លៃផលប៉ះពាល់ សង្គមនិងបរិស្ថាន ហើយត្រូវស្របតាមច្បាប់គ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន ។ គួរឱ្យសាធារណជនចូលរួមផ្តល់យោបល់ទៅលើ របាយ-ការណ៍វាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ។

រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាអនុសាសន៍ចុងក្រោយរបស់របាយការណ៍ វាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ទាក់ទងទៅនឹងរាល់ការសម្រេចចិត្តចុងក្រោយទៅលើសកម្មភាពទាំងឡាយ នៅគ្រប់ប្រព័ន្ធកេរ្សគ្របរិស្ថានសំខាន់ៗ ហើយអាចបញ្ជាក់ប្រាប់សាធារណជនពីការសម្រេចចិត្តចុងក្រោយរបស់រាជរដ្ឋាភិបាលដោយយោងលើមាត្រានេះ ។

**មាត្រា៥:**

វាក្យសព្ទប្រើនៅក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសន្ទានុក្រម ដែលជាឧបសម្ពន្ធ័នៃច្បាប់ ។ បទបញ្ជា និងនីតិវិធីនៃការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្មនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៦:**

ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម គឺជាស្ថាប័នរដ្ឋសម្រាប់អនុវត្តរដ្ឋបាល និងគ្រប់គ្រងវិស័យកសិកម្ម និងធនធានកសិកម្មដោយយោងលើគោលនយោបាយកសិកម្មជាតិ និងច្បាប់នេះ ។

កិច្ចការគ្រប់គ្រង និងចាត់ចែងវិស័យកសិកម្មនៅថ្នាក់ខេត្ត ត្រូវបានកំណត់ដោយប្រកាសរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ មន្ត្រីទាំងឡាយរបស់អគ្គនាយកដ្ឋានកសិកម្ម ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យស្របទៅតាមគោលការណ៍តម្លាភាព ដោយធានាសិទ្ធចូលរួមធ្វើការសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ការអភិវឌ្ឍ និងការអភិរក្សកសិកម្ម ។

(រឺគួរបញ្ជាក់ដោយខ្លីបែបនេះ ការគ្រប់គ្រងរដ្ឋបាលកសិកម្ម វិស័យកសិកម្ម និងធនធានដីកសិកម្ម ដោយយោងលើគោលនយោបាយកសិកម្មជាតិ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ )

**មាត្រា៧:**

អគ្គនាយកដ្ឋានកសិកម្មត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោមៈ

១- ដាក់ចេញនូវគោលការណ៍ណែនាំទាំងឡាយ ទាក់ទងនឹងសកម្មភាពអភិបាលកិច្ចកសិកម្ម ដើម្បីធានានូវការគ្រប់គ្រងកសិកម្មប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ។

២- ប្រមូលទិន្នន័យកសិកម្មទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីកំណត់នូវផលិតភាពក្នុងកំរិតមួយប្រកបដោយនិរន្តរភាព ។

៣- កំណត់ពីព្រំប្រទល់ ចាត់ថ្នាក់ និងកំណត់តំបន់ដីកសិកម្មដើម្បីបង្កើតផែនទីប្រើប្រាស់ដី កសិកម្ម ដោយសហការជាមួយក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ។

៤- បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់ថ្នាក់ដីកសិកម្ម ផែនការប្រើប្រាស់ដី និងការអភិវឌ្ឍដី និងដើម្បីធ្វើការបញ្ជាក់ពីតំបន់សម្រាប់ការប្រើប្រាស់ដីកសិកម្ម ។

៥- រៀបចំ និងអនុវត្តផែនការគ្រប់គ្រងកសិកម្មជាតិ ដោយសហការជាមួយអាជ្ញាធរគ្រប់កម្រិតដែលពាក់ព័ន្ធជាមួយការគ្រប់គ្រងវិស័យកសិកម្ម ។

៦- ជម្រុញការអនុវត្តកសិកម្មនៅលើដីដែលទុកចោលទំនេរ ឬ ដីធ្លាប់ប្រើប្រាស់សម្រាប់កសិកម្មដែលមិនស្ថិតនៅក្នុងផ្នែកណាមួយនៃផែនការ ឬដំណើរការជាលក្ខណៈប្រពៃណីនៃការធ្វើឱ្យប្រសើរឡើងវិញដល់ដី ។

៧- ជម្រុញការអភិវឌ្ឍសហគមន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងកម្មវិធីកសិកម្ម និងតាមរយៈការផ្តល់ការគាំទ្រខាងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសសមស្របទៅដល់សហគមន៍ ។

៨- អនុវត្តវិធានការសមស្របដើម្បីតាមដាន ការពារ និងបង្ក្រាបការអនុវត្តកសិកម្ម ដែលមិនមាននិរន្តរភាព និងបំផ្លិចបំផ្លាញ និងការរានដីទុកចោលទំនេរ ដើម្បីធានាការពង្រឹង និងអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធិភាព ។

៩- ជម្រុញកម្មវិធីអប់រំសាធារណៈដែលបង្ហាញពីសារសំខាន់ដើម្បីគ្រប់គ្រង ថែរក្សា និងការពារធនធានកសិកម្ម ហើយក៏អនុវត្តការស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិឡើងវិញ និងអភិរក្សការប្រើប្រាស់ដីកសិកម្មផងដែរ ។

១០- ជម្រុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពការពារ និងអភិវឌ្ឍន៍ធនធានដីកសិកម្ម ។

១១- ធានាការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលានូវរាល់សកម្មភាពពាក់ព័ន្ធជាមួយកសិកម្មដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសង្គម និងបរិស្ថាន មុនមានការសម្រេចចិត្តទៅលើសកម្មភាពនោះ ។

អគ្គនាយកដ្ឋានកសិកម្មអាចសហការ និងជួយបង្កើតអង្គភាព-ស្ថាប័នអភិវឌ្ឍន៍ដីកសិកម្មនៅគ្រប់កម្រិតតាមតំបន់ផ្សេងៗ ដើម្បីផ្តល់ជំនួយបច្ចេកទេស ការធ្វើបង្ហាញ និងផ្តល់ជំបូន្មានដោយផ្ទាល់ដល់កសិករ ក្នុងករណី ដែលកន្លែងនោះមានមធ្យោបាយដើម្បី កែលំអដី និងទឹក ដែលបញ្ជាក់ដោយអគ្គនាយកដ្ឋានកសិកម្ម នៅក្រោមច្បាប់នេះ និងនៅកន្លែងណាដែលមិនអាចផ្តល់ជំបូន្មានជូនប្រជាកសិករបានដោយមធ្យោបាយដូចខាងលើ ។

## ជំពូកទី៣
## ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព

**មាត្រា៨:**

រូបវន្តបុគ្គល-នីតិបុគ្គល ដែលអនុវត្តការងារកសិកម្មនៅលើដីកន្លែងណាមួយនោះ ត្រូវមានភារកិច្ចអនុវត្តសកម្មភាពនោះប្រកបដោយនិរន្តភាព ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្តល់បច្ចេកទេសគាំទ្រ និងចេញការណែនាំស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មសមស្រប ដើម្បីជួយដល់ពួកគេសម្រេចបាននូវការតព្វកិច្ចទាំងឡាយនៃមាត្រានេះ ។

**មាត្រា៩:**

រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើត គោលនយោបាយដីកសិកម្មជាតិ ។ រូបវន្តបុគ្គល-នីតិបុគ្គលត្រូវអនុវត្តការគ្រប់គ្រងកសិកម្មប្រកបដោយនិរន្តរភាពឱ្យស្របទៅតាមគោលនយោបាយដីសិកម្មជាតិនិងបទប្បញ្ញត្តិនៃច្បាប់នេះ

ដើម្បីជួយដល់ការសិក្សា ស្រាវជ្រាវ និងរៀបចំគោលនយោបាយដីកសិកម្មជាតិប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើតគណៈកម្មការដីកសិកម្ម ដើម្បីរៀបចំ និងអនុវត្តគោលនយោបាយនេះ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសមាជិកមកពីក្រសួង-ស្ថាប័នពាក់ពន្ធ័ ។

ការរៀបចំ ការប្រព្រឹត្តទៅ និងតួនាទីរបស់គណៈកម្មការស្តីពីគោលនយោបាយដីកសិកម្មជាតិត្រូវកំណត់ដោយអនុក្រិត ។

ការបង្កើតគោលនយោបាយដីកសិកម្មជាតិ ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មការគោលនយោបាយដីកសិកម្មជាតិ ។ គោលនយោបាយដីកសិកម្មជាតិអាចកែសម្រួល ក៏ត្រូវផ្អែកលើអនុសាសន៍ពី គណៈកម្មការដីកសិកម្មជាតិ ប្រសិនបើមានការផ្លាស់ប្តូរជាសំខាន់នៅក្នុងលក្ខណ្ឌ និងពេលវេលានៃដីកសិកម្មដោយយោងលើគោលការណ៍គ្រប់គ្រងកសិកម្មប្រកបដោយនិរន្តរភាព។

**មាត្រា១០:**

ផែនការគ្រប់គ្រងដីកសិកម្មជាតិ ត្រូវជាផែនការដែលកំណត់យ៉ាងច្បាស់ ពេញលេញ និងក្នុងទម្រង់ សហការនូវសកម្មភាព និងការសម្រេចចិត្ត ដែលស្ថាប័នមានសមត្ថកិច្ច និងអង្គការផ្សេងៗទៀត មានភារកិច្ចពាក់ព័ន្ធជាមួយការគ្រប់គ្រងវិស័យកសិកម្ម ដែលស្មើឡើងនូវរយៈពេលនៃការអនុវត្តគោលនយោបាយដីកសិកម្មជាតិ និងគោលនយោបាយដទៃទៀតទាក់ទងជាមួយវិស័យកសិកម្ម ដែលអាចត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ដ៏ទៃ១ទៀតដែលពាក់ព័ន្ធជាមួយវិស័យកសិកម្ម។

មាតិការលំអិតនៃផែនការគ្រប់គ្រងដីកសិកម្មជាតិ និងវិធីសាស្រ្តនៃការរៀបចំត្រូវកំណត់ដោយអនុក្រឹត្យ ។ ដោយផ្អែកលើអនុសាសន៍ពីគណៈកម្មការជាតិសម្រាប់គោលនយោបាយដីកសិកម្ម រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា នូវរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តផែនការគ្រប់គ្រងដីកសិកម្មជាតិ ។ របាយការណ៍នេះត្រូវតែបោះពុម្ព និងអាចប្រើប្រាស់បានជាសាធារណៈ ។

**មាត្រា១១:**

គោលការណ៍សំខាន់សម្រាប់គ្រប់គ្រងដីកសិកម្មនៅកម្ពុជាដោយស្ថាប័នមានសមត្ថកិច្ច គឺការគ្រប់គ្រងតាមបែបសហគមន៍ ដែលជាវិធីសាស្រ្តដ៏សំបូរបែបក្នុងការគ្រប់គ្រងរួមគ្នា និងផ្តល់អំណាចដល់សហគមន៍ក្នុងស្រុកចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស ការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងបង្កើនផលិតភាពធនធានកសិកម្មតាមរយៈយុទ្ធសាស្រ្តផ្សេងៗ ដោយរួមទាំងសហគមន៍កសិកម្ម ការរៀបចំផែនការប្រើប្រាស់ដីកសិកម្មដោយមានការចូលរួម សហគមន៍តំបន់ការពារកសិកម្ម និងការគ្រប់គ្រង និងធ្វើផែនការរួមគ្នានៃតំបន់អភិវឌ្ឍន៍កសិកម្ម។

វាត្រូវតែជាតួនាទីរបស់មន្រ្តីជំនាញនៅក្នុងអគ្គនាយកដ្ឋានកសិកម្ម ដើម្បីជួយសហគមន៍ដែលមានបំណងដូចខាងលើ ដើម្បីបង្កើតសមាគម-សហគមន៍ ផ្អែកលើទស្សនៈរបស់គេ ដើម្បីជួយអភិវឌ្ឍន៍ និង គ្រប់គ្រងការងារកសិកម្ម ជាមួយនឹងគោលការណ៍បង្កើនទាំងផលិតភាព និងនិរន្តរភាពនៃការងារកសិកម្មក្នុងសហគមន៍។

ក្នុងដីសម្បទានសង្គមកិច្ច ដែលការដាំដុះគឺជាសកម្មភាពដ៏សំខាន់ សហគមន៍នៅក្នុងដីសម្បទានសង្គមកិច្ចត្រូវធ្វើសកម្មភាពតាមរយៈ និងតាមការផ្តល់ដំបូន្មាននិងជំនួយពីក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវរៀបចំផែនការសកម្មភាពរបស់សហគមន៍សម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងកសិកម្មនៅក្នុងដីសម្បទានសង្គមកិច្ច។ អគ្គនាយកដ្ឋានកសិកម្មត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងត្រួតពិនិត្យការអនុវត្តផែនការតាមការស្នើរសុំរបស់សហគមន៍។

នៅក្នុងបរិបទនៃគោលការណ៍ខាងលើ មន្ត្រីរបស់អគ្គនាយកដ្ឋានកសិកម្មត្រូវមានភារកិច្ចដោយឡែកដូចខាងក្រោម៖

១. បង្កើត និងដាក់ចេញគោលការណ៍ណែនាំទូទៅស្តីពីការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងប្រើប្រាស់ប្រភេទនិងចំណាត់ថ្នាក់ផ្សេងៗនៃដីកសិកម្ម។

២. ផ្តល់ដំបូន្មាន និងជួយដល់អ្នកប្រើប្រាស់ដីកសិកម្ម ស្តីពីការប្រើប្រាស់ និងពីរបៀបកែលំអដីកសិកម្មក្នុងន័យប្រើប្រាស់ប្រកបដោយនិរន្តរភាព និងផលិតភាពនៃដីឱ្យកាន់តែប្រសើរឡើង។

**មាត្រា១២៖**

តំបន់អភិរក្សជីវចម្រុះកសិកម្ម ត្រូវបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតាមរយៈការយល់ព្រមពីក្រសួង ដោយមានការពិគ្រោះយោបល់ជាមួយ ឬការស្នើសុំពីអាជ្ញាធរមូលដ្ឋាន ក្នុងគោល-បំណងធ្វើឱ្យមានសុវត្ថិភាពដល់កន្លែងប្រភពដើម និងតំណាងឱ្យធនធានសេណេទិចកសិកម្មក្នុងតំបន់ និង ប្រព័ន្ធអេកូឡូស៊ី ដូចនេះវាជាការអភិរក្ស និងការពារមរតិកកសិកម្មជាតិ។ មរតិកកសិកម្មជាតិ មិនកំណត់តែទៅលើប្រភេទដីផ្សេងៗទេ គឺអាចរួមបញ្ចូល ទាំងគ្រាប់ពូជដំណាំផ្សេងៗ រុក្ខជាតិផ្សេងៗ ប្រភេទឈើហូបផ្លែផ្សេងៗ ព្រៃគុម្ពោត និងរុក្ខជាតិ និងប្រភេទសត្វផ្សេងៗទុកសម្រាប់ជាអាហារ ដែលមានដើមកំណើតនៅ ឬមានវត្តមាននៅនឹងកន្លែងក្នុងរយៈពេលមួយកំណត់ ត្រូវបានដាំនៅកម្ពុជា ហើយកំពុងទទួលរងគ្រោះថ្នាក់បាត់បង់ដែលបណ្តាលមកពីការនាំចូលនូវវិធីសាស្ត្រកសិកម្មតាមបែបទំនើប គ្រាប់បង្កាត់ សរីរាង្គកែប្រែសេណេទិច ថ្នាំសម្លាប់សត្វល្អិត ថ្នាំកំចាត់ស្មៅ ជម្ងឺ សត្វល្អិតដែលមានពិស និងការនាំចូលនូវប្រភេទដែលមានគ្រោះថ្នាក់ដល់រុក្ខជាតិ និងការអនុវត្តដទៃទៀត សកម្មភាព ឬការងារផ្សេងទៀតដែលគ្រោះថ្នាក់ដល់មរតិកកសិកម្មជាតិ។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវសិក្សា និងវាយតម្លៃដីរដ្ឋដែលប្រើប្រាស់សម្រាប់កសិកម្មដើម្បីដឹងថា តើដីនោះសមស្របសម្រាប់តំបន់អភិរក្សជីវៈចម្រុះកសិកម្ម និងត្រូវកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ទៅលើដីដែលត្រូវបានចាត់ទុកថាជាតំបន់អភិរក្សនោះ។

តំបន់អភិរក្សជីវៈចម្រុះកសិកម្មអាចត្រូវបានបង្កើតឡើងនៅក្នុងដីកសិកម្មរបស់រដ្ឋ ប៉ុន្តែកន្លែងដែលដីត្រូវបានប្រើប្រាស់ឬកំពុងត្រូវបានកាន់កាប់និងប្រើប្រាស់ដោយបុគ្គលឬស្ថាប័នទាំងឡាយ បុគ្គលឬស្ថាប័ននោះ ត្រូវតែបានពិភាក្សាអំពីការបង្កើតតំបន់អភិរក្ស ហើយប្រសិនបើក្រោយពីការពិភាក្សា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបង្កើតតំបន់អភិរក្សនោះ សំណងដ៏សមស្របមួយត្រូវតែបង់ក្នុងការយកដីពីបុគ្គល និងស្ថាប័នទាំងនោះ ហើយគ្មានបុគ្គល ឬស្ថាប័នណាមួយត្រូវបានទាមទារប្រគល់ដីឱ្យគេក្នុងគោលបំណងសម្រាប់ធ្វើជាតំបន់អភិរក្សទេ រហូតដល់សំណងត្រូវបានធ្វើចប់សព្វគ្រប់។

អគ្គនាយកដ្ឋានកសិកម្ម ដោយមានការព្រមព្រៀងគ្នាជាមួយអាជ្ញាធរមូលដ្ឋាន ត្រូវធ្វើការកំណត់ថាតើកន្លែងណាជាកន្លែងត្រូវបង្កើតតំបន់អភិរក្សជីវៈចម្រុះកសិកម្ម រៀបចំផែនការសម្រាប់គ្រប់គ្រង និងប្រើប្រាស់ដីដែលមាននៅក្នុងតំបន់។ លក្ខណៈពិសេសរបស់ផែនការខាងលើ ដែលបានរៀបចំក្រោមមាត្រានេះត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា១៣:**

រាល់ធនធានជីវៈទាំងអស់ និងផលិតផលរបស់វា ទោះជាកើតឡើងដោយធម្មជាតិ ឬការផ្សាំនៅលើ ឬក្នុងដីកសិកម្មនៅកម្ពុជា រួមទាំងធនធានសេណេទិចដែលជារបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវតែអភិរក្ស និងប្រើប្រាស់សម្រាប់ប្រជាជនកម្ពុជាឱ្យស្របទៅតាមច្បាប់នេះ និងច្បាប់ផ្សេងទៀតស្តីពីធនធានជីវៈចម្រុះ។

ការផ្លាស់ប្តូរដែលមិនមានការអនុញ្ញាតនូវធនធានជីវៈចម្រុះណាមួយ ផលិតផលដែលកើតចេញពីធនធានជីវៈឬផ្នែកផ្សេងទៀតពីដីកសិកម្មនៅកម្ពុជាគឺមិនត្រូវធ្វើដោយបំបាត់នូវអធិបតេយ្យភាពកម្ពុជាតាមរយៈធនធានទាំងនោះឡើយ។

## ជំពូកទី៤
## តំបន់អភិវឌ្ឍន៍កសិកម្ម

**មាត្រា១៤:**

ដីតំបន់អភិវឌ្ឍន៍កសិកម្មខ្នាតតូចត្រូវបានបង្កើតឡើង អាចជាដីឯកជនតែមួយ ឬប្រមូលផ្តុំដោយម្ចាស់ដីដែលជាកសិករខ្នាតតូច ឬជួលដោយកសិករពីដីឯកជនរបស់រដ្ឋ ឬពីដីសាធារណៈរបស់រដ្ឋ ឬពីដីឯកជន។ តំបន់អភិវឌ្ឍន៍កសិកម្មគឺជាតំបន់កាន់កាប់ និងប្រើប្រាស់ដោយកសិករខ្នាតតូចដែលពួកគេត្រូវការជំនួយ ដើម្បីបង្កើនផលិតភាពរបស់គេប្រកបដោយនិរន្តរភាព និងអភិវឌ្ឍន៍ផលិតផលកសិកម្មសម្រាប់ទីផ្សារ ដើម្បីកែលំអជីវភាព និងប្រាក់ចំណូលរបស់គេ។

**មាត្រា១៥:**

តំបន់អភិវឌ្ឍន៍កសិកម្មអាចត្រូវបានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈការស្នើសុំពីអគ្គនាយកដ្ឋានកសិកម្មដោយមានការពិគ្រោះយោបល់ជាមួយ ឬការស្នើសុំពីអាជ្ញាធរមូលដ្ឋាន ។ ត្រូវវាយតម្លៃ និងសិក្សាដីដែលបានប្រើប្រាស់សម្រាប់កសិកម្ម និងកសិករដែលប្រើប្រាស់ដីនោះ ដើម្បីដឹងថាតើដីនោះសមស្របសម្រាប់អភិវឌ្ឍន៍កសិកម្ម ហើយថាតើកសិករខ្នាតតូចចាប់អារម្មណ៍ និងមានឆន្ទៈចូលរួមក្នុងតំបន់អភិវឌ្ឍន៍កសិកម្មដែរឬទេ និងត្រូវកំណត់ព្រំប្រទល់ដែលសមស្របសម្រាប់គោលបំណងនេះឱ្យបានច្បាស់លាស់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពន្យល់កសិករខ្នាតតូចនូវអ្វី ដែលជាការរំពឹងទុករបស់គេដែលជាផលប្រយោជន៍បានពីតំបន់អភិវឌ្ឍន៍កសិកម្ម ហើយតើធាតុចូលអ្វីខ្លះនឹងត្រូវផ្តល់ដោយអគ្គនាយកដ្ឋាន-កសិកម្ម ដើម្បីជួយគេកែលំអផលិតភាពកសិកម្ម បង្កើនប្រាក់ចំណូល និង កែលំអជីវភាពរស់នៅរបស់ពួកគេ។

តំបន់អភិវឌ្ឍន៍កសិកម្មអាចត្រូវបានបង្កើតឡើងតែម៉្យាងគត់ប្រសិនបើ  កសិករខ្នាតតូចភាគច្រើននៅក្នុងតំបន់ដែលបានស្នើសុំបញ្ជាក់យ៉ាងច្បាស់ (ក្រោយពេលសំណើគម្រោងត្រូវបានពន្យល់ទៅគេ ហើយគេមានឱកាសពិភាក្សាសំណើគម្រោងជាមួយបុគ្គល និងស្ថាប័នទាំងឡាយនៅពេលដែលគេពិចារណានឹងជួយពួកគេ ដើម្បីធ្វើការសម្រេចចិត្ត) ថាពួកគេចង់បង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ហើយដូចនេះគេត្រូវធ្វើការសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ដើម្បីអនុវត្តផែនការតំបន់អភិវឌ្ឍន៍កសិកម្មនេះ ។

**មាត្រា១៦:**

ប្រសិនបើមានអង្គការកសិករខ្នាតតូចមួយឬច្រើនស្រាប់ នៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម អគ្គនាយកដ្ឋានកសិកម្មនឹងប្រើប្រាស់អង្គការទាំងនោះដើម្បីអនុវត្តកាតព្វកិច្ចក្រោមជំពូកនេះរបស់ច្បាប់ ។

ប្រសិនបើមិនមានអង្គការកសិករខ្នាតតូចមួយឬច្រើនស្រាប់ នៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម អគ្គនាយកដ្ឋានកសិកម្មនឹង (ដោយសហការជាមួយឃុំ-សង្កាត់ដែលមានការសម្រេចចិត្តនៅក្នុងតំបន់) ជួយកសិករខ្នាតតូចបង្កើតអង្គការកសិករខ្នាតតូចមួយឬច្រើន ដែលជាអង្គការតំណាងឱ្យកសិករខ្នាតតូចក្នុងការរៀបចំ និងអនុវត្តផែនការតំបន់អភិវឌ្ឍន៍កសិកម្ម ។

**មាត្រា១៧:**

ក្រោយបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម អគ្គនាយកដ្ឋានកសិកម្ម និងអង្គការកសិករខ្នាតតូចគួររៀបចំរួមគ្នានូវផែនការតំបន់អភិវឌ្ឍន៍កសិកម្មដែលកំណត់សកម្មភាពដើម្បីអនុវត្ត នណាជាអ្នកទទួលខុសត្រូវអនុវត្តសកម្មភាពដំណើរការ និងនីតិវិធីសម្រាប់អនុវត្តនីសកម្មភាព រយៈពេលដែលត្រូវអនុវត្តសកម្មភាពនិមួយៗ និងលទ្ធផលរយៈពេលវែងដែលរំពឹងទុកថាត្រូវសម្រេចបាន ដែលជាលទ្ធផលនៃការអនុវត្តសកម្មភាពទាំងឡាយ ដើម្បីបង្កើនផលិតភាពកសិករខ្នាតតូចក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម និងកែលំអន្នូវជីវភាពរបស់គេ ។

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍តំបន់កសិកម្ម ការយកចិត្តទុកដាក់គួរផ្តោតទៅលើការអនុវត្តកសិកម្មដែលមានស្រាប់របស់កសិករខ្នាតតូចនៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម ហើយការអនុវត្តទាំងនោះ (ប្រសិនបើមិនមានការបង្ហាញឱ្យបានច្បាស់លាស់ទេដោយឬពីភស្តុតាងដែលអាចបញ្ជាក់បានថាវិធីសាស្ត្រទាំងនោះ មិនមានផលប៉ះពាល់ជាអវិជ្ជមានទៅលើនិរន្តរភាព ឬមានការលំបាកក្នុងការកែលំអផលិតភាព) ត្រូវបានគេបង្កើតឡើង និងប្រើប្រាស់នៅក្នុងផែនការ ។

ផែនការអភិវឌ្ឍន៍កសិកម្មមិនអាចប្រតិបត្តិបានទេប្រសិនបើគ្មាន និងរហូតដល់ផែនការនោះ ត្រូវបានយល់ព្រមដោយកសិករខ្នាតតូចភាគច្រើនកាន់កាប់ និងប្រើប្រាស់ដីសម្រាប់គោលបំណងកសិកម្ម នៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្មនេះ ។

លក្ខណៈពិសេសដែលបានលំអិត និងមាតិកានៃផែនការអភិវឌ្ឍន៍កសិកម្ម និងវិធីនៃការប្រឹក្សាជាមួយកសិករខ្នាតតូចក្នុងកំឡុងពេលនៃការរៀបចំ និងអនុវត្តផែនការត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា១៨:**

កន្លែងដែលផែនការអភិវឌ្ឍន៍កសិកម្មត្រូវបានយល់ព្រមតាមមាត្រា១៧ ហើយដាក់ឱ្យប្រតិបត្តិ វាត្រូវជាភារកិច្ចរបស់កសិករខ្នាតតូចទាំងអស់នៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម ដើម្បីសហការ និងធ្វើការជាមួយមន្ត្រីរបស់អគ្គនាយកដ្ឋានកសិកម្ម ។ អគ្គនាយកដ្ឋានកសិកម្មក្នុងការអនុវត្តផែនការ ហើយនៅកន្លែងដែលផែនការទាមទារនូវសកម្មភាពពិតប្រាកដណាមួយ ដែលត្រូវអនុវត្តដោយកសិករខ្នាតតូចដើម្បីនាំមកនូវការកើនឡើងផលិតផលកសិកម្មប្រកបដោយនិរន្តរភាព ដើម្បីឱ្យស្របតាមការណែនាំរបស់មន្ត្រីទាំងនោះ។

កន្លែងដែលផែនការអភិវឌ្ឍន៍កសិកម្មត្រូវបានយល់ព្រមតាមមាត្រា១៨ ហើយដាក់ចូលប្រតិបត្តិ វាត្រូវជាភារកិច្ចរបស់មន្ត្រីអគ្គនាយកដ្ឋានកសិកម្ម ដែលធ្វើការក្នុងឬនៅតំបន់អភិវឌ្ឍន៍កសិកម្ម ដើម្បីធ្វើការតាមបែបសហការ និងគាំទ្រជាមួយកសិករខ្នាតតូចដោយពន្យល់គេឱ្យបានច្បាស់លាស់ពីគោលបំណង និងទិសដៅនៃកម្មភាពដែលត្រូវបានគេស្នើ ឬទាមទារឱ្យអនុវត្ត ដោយពិចារណាលើមតិយោបល់នានា ឬសំណើដែលអាចធ្វើឡើងដោយកសិករខ្នាតតូចដោយគោរពរាល់សកម្មភាពដែលពួកគេបានទាមទារឱ្យអនុវត្ត ឬថាពួកគេមានបំណងឱ្យមន្ត្រីមានសមត្ថកិច្ចដើម្បីអនុវត្ត និងជួយពួកគេដើម្បីអនុវត្តសកម្មភាពដែលបានស្នើឡើង។

## ជំពូកទី៥

## ការអភិរក្សធនធានដី

**មាត្រា១៩:**

គោលបំណងនៃការអភិរក្សធនធានដីគឺ:

១. កែលំអការអភិរក្ស ការស្តារឡើងវិញ និងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព និងថែរក្សាគុណភាពដី

២. ជម្រុញការប្រើប្រាស់ដីប្រកបដោយនិរន្តរភាពដោយយកចិត្តទុកដាក់ទៅលើស្ថិរភាពនៃអេកូឡូស៊ីបរិស្ថានល្អនៃដី។

៣. ធានាថាដី គឺត្រូវបានប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវអេកូឡូស៊ី ប្រើប្រាស់នូវបមាណីអេកូឡូស៊ីដែលសមស្រប ដោយរួមបញ្ចូលទាំងតម្លៃពីចំណេះដឹង និងការអនុវត្តការប្រើប្រាស់ដីតាមបែបប្រពៃណីជនជាតិ និងសហគមន៍មូលដ្ឋាន។

៤. ត្រួតពិនិត្យសកម្មភាពនៃការប្រើប្រាស់ដី ដើម្បីកំណត់ និងដោះស្រាយនូវបែបបទថ្មីនៃឱនភាពដីនៅក្នុង

ដំណាក់កាលដំបូងបំផុតដែលអាចធ្វើបាន ។

៥. លើទឹកចិត្តការអភិរក្សធនធានដីតាមរយៈការគ្រប់គ្រងដីតាមបែបសហគមន៍

**មាត្រា២០:**

ច្បាប់នេះអនុវត្តទៅលើដីទាំងអស់ដែលបានប្រើប្រាស់សម្រាប់ការងារកសិកម្ម និងកន្លែងដែលដីមិនមែនជាកម្មវត្ថុសម្រាប់ការអភិវឌ្ឍជាលំនៅដ្ឋានទីក្រុង សម្រាប់ឧស្សាហកម្ម និងសម្រាប់គោលបំណងដទៃទៀត ក្រោយពេលដីទាំងនោះត្រូវបានបំលែងមកជាដីកសិកម្ម ។

**មាត្រា២១:**

អគ្គនាយកដ្ឋានកសិកម្មនឹងត្រូវទទួលខុសត្រូវក្នុងការរៀបចំផែនការគ្រប់គ្រងថែរក្សា និងអភិរក្សធនធានដីថ្នាក់ជាតិ ដែលគោលបំណងនៃផែនការនេះគឺ:

១. វាយតម្លៃស្ថានភាព និងនិន្នាការឱនភាពដី

២. កំណត់ពីសូចនាករនៃផលប៉ះពាល់ និងឧបករណ៍ក្នុងការត្រួតពិនិត្យ

៣. ផ្តល់នូវគោលការណ៍ណែនាំដើម្បីអភិវឌ្ឍ និងអនុវត្តគោលនយោបាយដីកសិកម្មជាតិ និងយុទ្ធសាស្ត្រថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដី និងកែលំអគុណភាពដីនិងការអភិរក្សដី ។

៤. ធានាដល់ការរួមបញ្ចូលបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងដីទាំងអស់ទៅក្នុងកម្មវិធីអភិវឌ្ឍន៍

៥. អភិវឌ្ឍនការអប់រំសាធារណៈ និងកម្មវិធីចំណេះដឹងស្តីពីសារសំខាន់នៃការអភិរក្សធនធានដី

៦. លើកកំពស់និងគាំទ្រការរីកចំរើននិងសកម្មភាពការគ្រប់គ្រងដីតាមបែបសហគមន៍ និងក្រុមកសិករ

៧. ផ្តល់អនុសាសន៍សមស្រប និងឧបករណ៍ច្បាប់បន្ថែមទៀត ដើម្បីជួយសម្រួល និង អនុវត្តច្បាប់លើការអភិរក្សធនធានដី ។

ក្នុងការរៀបចំផែនការគ្រប់គ្រងថែរក្សា និងអភិរក្សធនធានដីថ្នាក់ជាតិ អគ្គនាយកដ្ឋានកសិកម្ម នឹងប្រើប្រាស់ដំណើរការដែលមានការចូលរួម និងតម្លាភាព ដោយរួមបញ្ចូលអាជ្ញាធរមូលដ្ឋាន សហគមន៍កសិករខ្នាតតូច សហគមន៍គ្រប់គ្រងដី សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច និងអង្គការផ្សេងៗទាំងអស់ដែលមានជំនាញ និងចំណាប់អារម្មណ៍ទៅលើបញ្ហាគុណភាពដី ការអភិរក្សដី និងការថែរក្សាដី ត្រូវអញ្ជើញអង្គការទាំងអស់ដូចបានរៀបរាប់នៅក្នុងមាត្រានេះ ដើម្បីដាក់ជូននូវទស្សនៈរបស់គេ ទៅលើបញ្ហាទាំងឡាយខាងលើហើយដែលត្រូវមាននៅក្នុងផែនការគ្រប់គ្រងថែរក្សា និងអភិរក្សធនធានដីថ្នាក់ជាតិ និងផ្តល់យោបល់ ទៅលើសេចក្តីព្រាងនៃផែនការគ្រប់គ្រងថែរក្សា និងអភិរក្សធនធានដីថ្នាក់ជាតិ ។

ផ្អែកលើអនុសាសន៍ពីអគ្គនាយកដ្ឋានកសិកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការគ្រប់គ្រងថែរក្សា និងអភិរក្សធនធានដីថ្នាក់ជាតិ ទៅរាជរដ្ឋាភិបាលកម្ពុជា។ របាយការណ៍នេះត្រូវបោះពុម្ព និងអាចផ្តល់ជូនជាសារធារណៈប្រើប្រាស់បាន ។

**មាត្រា២២:**

មធ្យោបាយសំខាន់ៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិរក្សធនធានដី ត្រូវបានអនុវត្តតាមរយៈបណ្តាញសមាគម និងក្រុមគ្រប់គ្រងថែរក្សាដី ហើយអគ្គនាយកដ្ឋានកសិកម្មត្រូវមានភារកិច្ចជួយក្រុម និងសមាគមកសិករទាំងនោះដោយធ្វើការជាមួយពួកគេ ដើម្បីធានាថាអ្នកកាន់កាប់ដីទាំងអស់យល់ពីគោលការណ៍នៃការគ្រប់គ្រងថែរក្សាដី និងបញ្ចូលគោលការណ៍ទាំងនោះទៅក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីរបស់ពួកគេ ។

**មាត្រា២៣:**

រាល់អ្នកកាន់កាប់ដីទាំងអស់ (ក្នុងករណីដីរបស់ម្ចាស់ដី) ត្រូវមានភារកិច្ចចាត់វិធានការសមស្រប:

១. ដើម្បីការពារការបាត់បង់ គុណភាព និងផលិតភាពដី ឬការធ្វើឱ្យមានឱនភាពដីតាមរយៈការអនុវត្តមិនសមស្រប ឬ

២. ប្រសិនបើការបាត់បង់ គុណភាព និងផលិតភាពដី ឬការធ្វើឱ្យមានឱនភាពដីកើតមានឡើងនោះ ត្រូវបញ្ឈប់សកម្មភាពទាំងនោះ ។

**មាត្រា២៤:**

ប្រសិនបើអគ្គនាយកដ្ឋានកសិកម្ម យល់ស្របថាវិធានការសមស្របមិនត្រូវបានអនុវត្តទេ:

ក) ដើម្បីការពារការបាត់បង់ គុណភាព និងផលិតភាព ដី ឬការធ្វើឱ្យមានឱនភាពដី តាមរយៈការអនុវត្តមិនសមស្របឬ

ខ) ក្នុងករណីដែលការបាត់បង់ គុណភាព និងផលិតភាពដី ឬការធ្វើឱ្យមានឱនភាពដីកើតមានឡើង ឬត្រូវបញ្ឈប់សកម្មភាពនោះ អគ្គនាយកដ្ឋានកសិកមអាចស្នើ ឬបញ្ជាឱ្យម្ចាស់ដីឱ្យមានការអភិរក្សធនធានដី ឆ្ពោះទៅរកការអនុវត្តវិធានការកែលំអដែលបានដាក់ចេញនៅក្នុងបទបញ្ជា ។

ប្រសិនបើអ្នកកាន់កាប់ដីមិនមែនជាម្ចាស់ដីដោយផ្អែកលើបទបញ្ជាដែលបានប្រគល់ជូន អគ្គនាយកដ្ឋានកសិកម្មអាចផ្តល់បទបញ្ជាមួយច្បាប់ជូនដល់ម្ចាស់ដីដើម ។

កន្លែងដែលអ្នកកាន់កាប់ដីមិនអនុវត្តតាមបទបញ្ជាដូចក្នុងរយៈពេលកំណត់ក្នុងបទបញ្ជា អគ្គនាយក-ដ្ឋានកសិកម្មអាចចូលទៅលើដីដែលបានបញ្ជាក់នៅក្នុងបទបញ្ជា ហើយអនុវត្តវិធានការកែលំអ ដែលបានកំណត់នៅក្នុងបទបញ្ជា ។

វិធានការដែលនៅសេសសល់ត្រូវពាក់ព័ន្ធជាមួយបញ្ជាដែលបានកំណត់ក្នុងមាត្រា២៥ ដែលមានក្នុងបទបញ្ជាអភិរក្សធនធានដី និងត្រូវដឹកនាំទៅរកការធានាថាបញ្ជាទាំងនោះត្រូវបានអនុវត្តដោយបុគ្គល ដែលបទបញ្ជាអភិរក្សធនធានដីត្រូវបានធ្វើឡើង ។

មាតិការលំអិតនៃការអភិរក្សធនធានដី និងបទបញ្ជានិងវិធានការកែលំអទាំងឡាយដែលចាំបាច់ នៅក្នុងបទបញ្ជាអាចត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា២៥:**

បទបញ្ជាការពារធនធានដីធ្វើឡើងសម្រាប់បញ្ហាដូចខាងក្រោម:

១- ហាមឃាត់ ការដាក់កម្រិត ឬការត្រួតត្រា និងការកាប់រានដីសម្រាប់ដាំដុះ

២- ការដុត ការកាប់ ឬការបំផ្លាញប្រភេទរុក្ខជាតិ-ដំណាំ

មានការហាមឃាត់ ការដាក់កម្រិត ឬការត្រួតពិនិត្យ ក្នុងករណីមន្ត្រីរកឃើញថាជាការចាំបាច់:

ក. សម្រាប់ការពារដីដើម្បីទប់ទល់ខ្យល់ ឬទឹកជំនន់

ខ. សម្រាប់ការអភិរក្សដី

គ. សម្រាប់ការពារការហូរច្រោះដី ឬការហូរចាក់គ្របដោយខ្សាច់ ថ្ម ឬគ្រួស

ឃ. សម្រាប់ការពារផ្លូវ និងស្ពាន

ង. សម្រាប់ការពារដី និងដីជាតិដី

៣. ភាពចាំបាច់ក្នុងការដាក់កម្រិត ឬការត្រួតពិនិត្យ

ក.ការដាំព្រៃឈើឡើងវិញ ឬការដាំឈើលើដីទំនេរ

ខ. ការពារតំបន់រងទឹកភ្លៀង

គ. ផ្លូវទឹករបស់ដី ដោយរួមបញ្ចូលការសាងសង់ ថែរក្សា ឬជួសជុលផ្លូវទឹកធម្មជាតិឬសប្បនិម្មិត

៤. ការទាមទារនូវការកាប់រំលើង ឬការបំផ្លាញដោយគ្មានសំណងចំពោះដំណាំដែលបានដាំ ឬអនុញ្ញាតឱ្យដាំដោយល្មើសទៅនឹងបទបញ្ជាការពារធនធានដី

៥. ហាមឃាត់ រឹតបន្តឹង និងត្រួតពិនិត្យការប្រើប្រាស់ដីកសិកម្ម

៦. បង្កើតតំបន់ទ្រទ្រង់ជីវសុវត្ថិភាព

ក្នុងការសម្រេចចិត្តថាតើត្រូវដាក់ចេញនូវបទបញ្ជាអភិរក្សធនធានដីដល់ម្ចាស់ដី អគ្គនាយកដ្ឋានកសិកម្ម រឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវ:

១. គិតទៅដល់ភាពជាក់ស្តែងនៃសកម្មភាពរបស់ម្ចាស់ដី

២. កំណត់ក្នុងបទបញ្ជាថាតើសកម្មភាពអ្វីដែលត្រូវធ្វើ

៣. ថាតើម្ចាស់ដីត្រូវនិងមិនត្រូវធ្វើអ្វីខ្លះដើម្បីគោរពទៅតាមបទបញ្ជា

៤. ពេលវេលាមិនតិចជាងមួយខែ ដែលក្នុងពេលនេះបទបញ្ជាត្រូវបានគោរព

៥. ផលវិបាកដែលមិនគោរពទៅតាមបទបញ្ជា

## ជំពូកទី៦

## ការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មរបស់សហគមន៍ជាលក្ខណ:ប្រពៃណី

**មាត្រា២៦:**

កសិកម្មពនេចរ គឺជាប្រព័ន្ធដាំដុះជាលក្ខណៈប្រពៃណីដែលវិលជុំលើវាលស្រែ ចំការ និង ទីវាលទំនេរទាំងឡាយដែលអនុញ្ញាតឱ្យកន្លែងភាគច្រើននៃប្រព័ន្ធនេះស្ថិតនៅទំនេរមិនមានដំណាំអ្វី ក្នុងគោលបំណងសម្រាប់បង្កើតឡើងវិញនូវសារធាតុចិញ្ចឹម ។ កសិកម្មពនេចរមិនអនុញ្ញាតស្ថិតនៅក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋទេ ។ និរន្តរភាពនៃការប្រើប្រាស់ដី និងការអភិរក្សដីគឺត្រូវបានធានាដោយដំណើរការធម្មជាតិដោយខ្លួនឯង និងទុកដីឱ្យសម្រាក និងកកើតជីជាតិឡើងវិញ ។

កសិកម្មពនេចរ គឺត្រូវបានគ្រប់គ្រងដោយមេក្រុម ដែលគេទទួលស្គាល់នៅក្នុងសហគមន៍ដែលអនុវត្តការងារនោះ ។កសិកម្មពនេចរគឺត្រូវទទួលស្គាល់ដោយច្បាប់ថាជាការប្រើប្រាស់ដីសម្រាប់គោលបំណងកសិកម្ម ។

បទប្បញ្ញត្តិសម្រាប់ការបែងចែក និងប្រើប្រាស់ដីសម្រាប់កសិកម្មពនេចរគឺត្រូវបានធានាដោយច្បាប់ ។

**មាត្រា២៧:**

អគ្គនាយកដ្ឋានកសិកម្មត្រូវទទួលស្គាល់កសិកម្មពនេចរថាជាទម្រង់ស្ថិតស្ថេរមួយសម្រាប់ការប្រើប្រាស់ដីកសិកម្ម ដែលជាកន្លែងដែលប្រតិបត្តិផ្តល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងផ្តល់ជីវភាពរស់នៅដល់សមាជិកនៃសហគមន៍ជាលក្ខណៈប្រពៃណី ។

អគ្គនាយកដ្ឋានកសិកម្មត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ប្រពៃណី និងប្រធានក្រុមរបស់គេក្នុងការបង្កើតកម្មវិធី ដែលរៀបចំឡើងដើម្បីកែលំអផលិតភាពកសិកម្មរបស់គេតាមរយៈបែបបទ ដែលកាន់តែមានប្រសិទ្ធភាពនៃកសិកម្មពនេចរ ។

នៅកន្លែងដែលមានភស្តុតាងច្បាស់លាស់ពីការផ្លាស់ប្តូរការអនុវត្តកសិកម្ម (ឬទស្សនៈ) នៅក្នុងសហគមន៍ប្រពៃណី និងមេដឹកនាំរបស់គេបង្ហាញដល់អគ្គនាយកដ្ឋានកសិកម្ម ឬវេទិកាផ្សេងទៀត ដែលសហគមន៍ប្រពៃណីកំពុងតែមានចលនាផ្លាស់ប្តូរពីកសិកម្មពនេចរ ដើម្បីចាប់យកឱកាសទីផ្សារខាងផ្នែកកសិកម្ម ដោយប្តូរទៅជាការដាំដំណាំសម្រាប់ធ្វើពាណិជ្ជកម្ម អគ្គនាយកដ្ឋានកសិកម្ម និងស្ថាប័នពាក់ពន្ធ័ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយ សហគមន៍ ឬសហគមន៍ប្រពៃណីទាំងនោះ និងប្រធានក្រុមរបស់ពួកគេ ក្នុងការបង្កើតកម្មវិធី រួមទាំង (ប្រសិនបើការយល់ ស្របត្រូវបានគេធ្វើឡើង) បង្កើតកន្លែងអភិវឌ្ឍន៍កសិកម្ម ដែលរៀបចំឡើងដើម្បីសម្របសម្រួលការដាំដុះបន្ទាប់បន្សំនៃកសិកម្មពនេចរ រួមជាមួយការអនុវត្តកសិកម្មដែលកាន់តែសមស្របសម្រាប់កសិ-ពាណិជ្ជកម្ម ខណៈដែលការប្រើប្រាស់រាល់កិច្ចខិតខំប្រឹងប្រែងដើម្បីធានានិរន្តរភាពនៃតំបន់ និងការអភិរក្សដី ។

អគ្គនាយកដ្ឋានកសិកម្មត្រូវអនុវត្តនូវជំហានដ៏ចាំបាច់ទាំងឡាយដើម្បីធានាថាកម្មវិធីដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរបែបបទជាប្រពៃណីនៃកសិកម្មពនេចរត្រូវអភិវឌ្ឍ និងយល់ស្របគ្នាជាមួយប្រធានក្រុមនៃសហគមន៍ប្រពៃណី ត្រូវបានពន្យល់ដល់សមាជិកសហគមន៍ទាំងនោះនិងអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតយល់ព្រមជាមួយនឹងកិច្ចសហការនៃសមាជិករបស់សហគមន៍ទាំងនោះ ។

ក្នុងការអនុវត្តតួនាទីរបស់ខ្លួនក្រោមមាត្រានេះ អគ្គនាយកដ្ឋានកសិកម្មត្រូវប្រើកិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុត (ធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ប្រពៃណី និងប្រធានក្រុម) ដើម្បីបង្កើតសមាគមន៍កសិករខ្នាតតូច និងសមាគមគ្រប់គ្រងថែរក្សាដី ក្នុងចំណោមពួកគេទាំងនោះ នៅក្នុងកន្លែងដែលមានការផ្លាស់ប្តូរកសិកម្មពនេចរ ចាំជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដែលតំណាងឱ្យចំណាប់អារម្មណ៍របស់ពួកគេទាំងនោះ និងធានាការប្រើ-ប្រាស់ដីប្រកបដោយនិរន្តរភាព ។

**មាត្រា២៨:**

ចំពោះកន្លែងដែលកសិកម្មពនេចរមិនស្ថិតនៅក្នុងតំបន់ព្រៃឈើ ហើយមិនស្ថិតនៅក្នុងការគ្រប់គ្រងនិងសម្រេចចិត្ត របស់រដ្ឋបាលព្រៃឈើ និងគ្រប់គ្រងដោយមាត្រា៣៧នៃច្បាប់ស្តីពីព្រៃឈើ អគ្គនាយកដ្ឋានកសិកម្ម (សម្រាប់គោលបំណងអនុវត្តន៍តួនាទីរបស់ខ្លួនក្រោមច្បាប់នេះ ដោយគោរពតាមដីកសិកម្មនៃសហគមន៍ប្រពៃណី) ត្រូវចាត់ថ្នាក់ និងកំណត់ព្រំប្រទល់រដ្ឋបាល សម្រាប់កសិកម្មពនេចរទាំងអស់ដែលស្ថិត នៅក្រៅដែនព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ។ ក្នុងការអនុវត្តសកម្មភាពនេះ អគ្គនាយកដ្ឋានកសិកម្មត្រូវសម្របសម្រួលជាមួយសហគមន៍នៅនឹងកន្លែង តំណាងក្រុមសហគមន៍ប្រពៃណី អាជ្ញាធរពាក់ព័ន្ធ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលទទួលខុសត្រូវក្នុងការចុះបញ្ជីកម្មសិទ្ធិដីសហគមន៍។

## ជំពូកទី៧

## ផលិតកម្មកសិកម្មតាមកិច្ចសន្យា

**មាត្រា២៩:**

ជំពូកនេះមានគោលបំណង:

- ពង្រឹងភាពទទួលខុសត្រូវ និងភាពជឿជាក់រវាងភាគីផលិត និងភាគីទិញក្នុងន័យត្រឹមត្រូវនិងយុត្តិធម៌
- ធានាតម្លៃពិសេស និងការផ្គត់ផ្គង់ ទាំងបរិមាណ និងគុណភាពផលិតផលកសិកម្ម
- កែលំអការទិញ ការកែច្នៃ និងការនាំចេញផលិតផលកសិកម្ម

**មាត្រា៣០:**

ជំពូកនេះអនុវត្តទៅលើជំនួញផលិតផលកសិកម្មគ្រប់ប្រភេទ និងផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣១:**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជាស្ថាប័ននាំមុខក្នុងទំនាក់ទំនង សម្របសម្រួល ផ្តល់នូវសេវា ដែលស្ថិតក្រោមសមត្ថភាពរបស់ខ្លួន ចូលរួមរាល់សកម្មភាព ផ្តល់នូវលក្ខ័ណ្ឌសមស្របសម្រាប់ដើម្បីអភិ-វឌ្ឍន៍នូវផលិតកម្មកសិកម្មតាមកិច្ចសន្យា តាមដាននិងវាយតម្លៃ និងរៀបចំរបាយការណ៍ជាក់ជូនរាជរដ្ឋាភិបាល ។

**មាត្រា៣២:**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តតួនាទីដូចខាងក្រោម:

១. អូសទាញអ្នកវិនិយោគគិន កសិករ អ្នកផលិត និងអ្នកកែច្នៃ ដើម្បីទំនាក់ទំនងគ្នាក្នុងក្របខ័ណ្ឌផលិតកម្មកសិកម្មតាមកិច្ចសន្យា

២. ជម្រុញនិងលើកទឹកចិត្តការបង្កើតសមាគម សហគមន៍កសិកម្ម ឬអង្គការកសិកម្មធ្វើជាមូលដ្ឋាន ដើម្បីអភិវឌ្ឍផលិតកម្មកសិកម្មតាមកិច្ចសន្យា

៣. កែលំអបទដ្ឋាន ចាត់ថ្នាក់គុណភាពផលិតផលកសិកម្មឱ្យស្របតាមតម្រូវការទីផ្សារ និងបទដ្ឋានអន្តរជាតិ

៤. ត្រូវចូលរួមក្នុងការដោះស្រាយជម្លោះ បញ្ហាទាំងឡាយដែលទាក់ទងនឹងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយផ្អែកលើច្បាប់ដែលមានស្រាប់

៥. សម្របសម្រួលដល់កម្មសិទ្ធស្របច្បាប់ដោយផ្អែកលើច្បាប់ដែលមានស្រាប់ដល់ភាគីផលិត និងដាំដុះដើម្បីអនុវត្តនូវកសិពាណិជ្ជកម្ម និងកសិឧស្សាហកម្ម

៦. ផ្តល់នូវលក្ខ័ណ្ឌសមស្របដើម្បីប្រើប្រាស់នូវសេវាកម្មគាំទ្របច្ចេកទេស គ្រាប់ពូជដែលមានគុណភាពល្អ ប្រភេទវារីសត្វ ប្រភេទរុក្ខជាតិ ការបង្កាត់ពូជសត្វ មធ្យោបាយផលិតកម្ម ជីដែលមានគុណភាពខ្ពស់ ថ្នាំកសិកម្ម

៧. ពង្រឹងផលិតកម្ម និងពិពិធកម្មកសិកម្ម ភាពប្រកួតប្រជែងរបស់ផលិតផល ដើម្បីបំពេញតម្រូវការទីផ្សារក្នុងស្រុក និងការនាំចេញ

៨. សម្របសម្រួលដល់កសិពាណិជ្ជកម្ម កសិឧស្សាហកម្ម និងការនាំចេញ

៩. ពង្រឹងនិងពង្រីកសមត្ថភាពត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ

**មាត្រា៣៣:**

ត្រូវបង្កើតគណៈកម្មការផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ការរៀបចំគណៈកម្មការនេះត្រូវកំណត់ដោយរាជរដ្ឋាភិបាលនិងសមាជិករបស់គណៈកម្មការត្រូវមកពីក្រសួង និងស្ថាប័នដូចមានខាងក្រោម: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបណីកម្ម និងសំណង់ ក្រសួងធនធានទឹកនិងឧត្តុនិយម ក្រសួងអភិវឌ្ឍន៍

ជនបទ ក្រសួងយុត្តិធម៌ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ អភិបាលរាជធានី-ខេត្ត ធនាគារអភិវឌ្ឍន៍ជនបទ សភាពាណិជ្ជកម្មកម្ពុជា ។ល។

គណៈកម្មការនេះត្រូវមានភារកិច្ចទទួលខុសត្រូវៈ

- រៀបចំផែនការយុទ្ធសាស្ត្រ និងគោលនយោបាយ ដើម្បីជម្រុញផលិតកម្មកសិកម្មតាមកិច្ចសន្យា

- សម្របសម្រួល និងពង្រឹងកិច្ចសហការរវាងភាគីផលិតកម្មកសិកម្មតាមកិច្ចសន្យា

- អន្តរាគមន៍ និងដោះស្រាយនូវជម្លោះ និងបញ្ហាទាំងឡាយដែលកើតឡើងពីផលិតកម្មកសិកម្មតាមកិច្ច-សន្យា ដែលភាគីនោះមិនអាចដោះស្រាយបានដោយខ្លួនឯង ឬត្រូវដោះស្រាយតាមរយៈអន្តរស្ថាប័ន។ គណៈ-កម្មការ ត្រូវសម្របសម្រួលដោយនាយកដ្ឋានកសិ-ឧស្សាហកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣៤ៈ**

ភាគីផលិតមានសិទ្ធ និងកាតព្វកិច្ចត្រូវៈ

- អនុវត្តតាមលក្ខ័ណ្ឌផលិតកម្មដោយផ្អែកលើកិច្ចព្រមព្រាង

- អនុវត្តតាមសកម្មភាពផលិតដោយផ្អែកលើរដូវកាល និងពេលវេលាកំណត់

- អនុវត្តបច្ចេកវិជ្ជា និងវិធីសាស្ត្រផលិតតាមតម្រូវការរបស់ភាគីអ្នកទិញ

- ផ្គត់ផ្គង់ផលិតផលទាន់ពេលវេលាក្នុងន័យ លំដាប់ថ្នាក់ គុណភាព និងបរិមាណ

- ទទួលយកនូវការទូទាត់តម្លៃផលិតផលតាមកិច្ចព្រមព្រាង

**មាត្រា៣៥ៈ**

ភាគីអ្នកទិញមានសិទ្ធ និងកាតព្វកិច្ចត្រូវៈ

- អនុវត្តតាមលក្ខ័ណ្ឌផលិតកម្មដោយផ្អែកលើកិច្ចព្រមព្រាង

- កំណត់មុខទំនិញដូចជា បរិមាណ គុណភាព ទីកន្លែង និងថ្ងៃខែត្រូវបញ្ជូន និងទទួលយកនូវផលិតផល

- ផ្តល់នូវការផ្គត់ផ្គង់ធាតុចូលកសិកម្មដូចជា ពូជបន្លែ គ្រាប់ ពូជវារីសត្វ ការបង្កាត់ពូជសត្វ និងផ្តល់នូវឥណទាន ផ្គត់ផ្គង់ជាមុននូវសេវាកម្មបច្ចេកទេស និងការគាំទ្រផ្សេងៗទៀតដល់ភាគីផលិតដើម្បីធានានូវដំណើរការ និងការទទួលយកនូវលទ្ធផលដ៏ល្អ

- បង់តម្លៃផលិតផលកសិកម្មដែលផ្តល់ជូនតាមបរិមាណ និងគុណភាពត្រឹមត្រូវដូចដែលបានព្រមព្រាង

- បង់ថ្លៃផលិតផលដល់ភាគីផលិតដូចបានកំណត់ក្នុងលក្ខ័ណ្ឌតាមពេលកំណត់ដូចដែលបានព្រមព្រាង

**មាត្រា៣៦:**

កិច្ចសន្យាសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវធ្វើឡើងជាលាយលក្ខ័អក្សរនិងត្រូវបានបញ្ជាក់និងអនុលោមតាមយន្តការសំរបសំរួលដែលរៀបរាប់ក្នុងមាត្រា៣៥។ កិច្ចសន្យាស្តីពីផលិតកម្មកសិកម្មតាមកិច្ច សន្យាត្រូវស្ថិតនៅក្រោមបញ្ញត្តិស៊ីវិល និងច្បាប់ដែលមានស្រាប់។

**មាត្រា៣៧:**

ប្រសិនមានជម្លោះឬបញ្ហាទាក់ទងនឹងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ភាគីផលិត និងអ្នកទិញត្រូវចរចារគ្នាជាមុនដោយផ្អែកលើលក្ខ័ណ្ឌរៀបរាប់នៅក្នុងកិច្ចសន្យា។ បើបញ្ហាមិនអាចដោះស្រាយបាន ភាគីទាំងពីរត្រូវអនុវត្តយន្តការដូចមានចែងក្នុងមាត្រា៣៥នៃច្បាប់នេះ។

## ជំពូកទី ៨
## កិច្ចសន្យាជួលដីកសិកម្ម

**មាត្រា៣៨:**

ការជួលដីកសិកម្មគឺជាប្រភេទជួលដូចតទៅ:

១. ការជួលដោយសម្បទានិក នូវដីសម្បទានដែលបានផ្តល់សម្រាប់គោលបំណងកសិ-ឧស្សាហកម្ម ទៅឱ្យនីតិ ឬរូបវ័ន្តបុគ្គលដើម្បីដាំដុះលើដីសម្បទាននោះ

២. ការជួលដែលបានផ្តល់ដោយអាជ្ញាធររដ្ឋាភិបាលពីដីដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទៅឱ្យនីតិ ឬរូបវ័ន្តបុគ្គល ដើម្បីបន្តការងារកសិកម្មលើដីដែលបានជួល។

៣. ជាការជួលដែលបានផ្តល់ដោយ នីតិ ឬរូបវ័ន្តបុគ្គលដែលមានដី ទៅឱ្យនីតិ ឬរូបវ័ន្តបុគ្គល ផ្សេងទៀតដើម្បីបន្តសកម្មការងារកសិកម្មលើដីដែលបានជួលនោះ ។

**មាត្រា៣៩:**

កិច្ចសន្យាជួលដីកសិកម្មត្រូវធ្វើឡើងជាលាយលក្ខ័អក្សរហើយត្រូវមាន:

១. ឈ្មោះ និងអាស័យដ្ឋានរបស់ភាគីទាំងឡាយ
២. ការជួលដែលបានផ្តល់ឱ្យ និងទីកន្លែង ពេលវេលា ដែលការជួលអាចបង់បាន
៣. រយៈពេលនៃការជួល
៤. ការពិពណ៌នាយ៉ាងច្បាស់ពីដីដែលមាននៅក្នុងកិច្ចសន្យាជួល
៥. លក្ខណ្ឌដូចដែលបានផ្តល់ជូននៅក្នុងច្បាប់នេះ
៦. លក្ខណ្ឌដទៃទៀតអាចត្រូវបានផ្តល់ជូនដោយអនុក្រឹត្យ

**មាត្រា៤០:**

អ្នកជួលបន្តអាច (នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ) ជួលបន្តទាំងអស់ ឬផ្នែកណាមួយនៃដីដែលមាននៅក្នុងកិច្ចសន្យាជួលទៅឱ្យអ្នកជួលបន្តផ្សេងទៀត ។

អ្នកជួលបន្តត្រូវតែដាក់ពាក្យសុំ និងទទួលការអនុញ្ញាតជាមុនពីម្ចាស់ដែលបានផ្តល់កិច្ចសន្យាជួល ទៅជួលដីបន្តណាមួយដែលមាននៅក្នុងកិច្ចសន្យាជួល ។

**មាត្រា៤១:**

លក្ខណ្ឌខាងក្រោមនៅក្នុងកិច្ចសន្យាជួលគឺអនុវត្តសម្រាប់អ្នកជួល:

១. តម្លៃឈ្នួលដែលអាចបង់បាននៅក្រោមច្បាប់នេះត្រូវបង់ដោយអ្នកជួល មិនយឺតជាងរយៈពេលនិមួយៗ ដូចដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាជួល ហើយក្នុងលក្ខណ្ឌដែលបានយល់ព្រមដោយភាគីទាំងឡាយ ។
២. អ្នកជួលមិនត្រូវបោះបង់ការជួល លើកលែងតែករណីដូចដែលបានអនុញ្ញាត និងផ្តល់សិទ្ធដោយបទប្បញ្ញត្តិនៃកិច្ចសន្យាជួល ។
៣. អ្នកជួលមិនត្រូវមានភាពជាម្ចាស់ក្នុងការ បញ្ចាំ កាត់ឈ្មោះ ជួលបន្ត ឬផ្ទេរសិទ្ធដី ឬផ្នែកណាមួយនៃដីដោយមិនមានការយល់ព្រមជាលាយលក្ខអក្សរពីម្ចាស់ដែលកាន់កាប់ពីមុន (ដែលការយល់ព្រមនោះមិនត្រូវបានដកហូតដោយមិនមានហេតុផលនោះឡើយ) ហើយត្រូវតែធ្វើទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។
៤. អ្នកជួលត្រូវអនុញ្ញាតឱ្យម្ចាស់ឬអ្នកដែលបានផ្តល់សិទ្ធដោយម្ចាស់ជាលាយលក្ខអក្សរ ចូលទៅលើដីដើម្បីពិនិត្យស្ថានភាព និងលក្ខណ្ឌនៃដីគ្រប់ពេលវេលាដែលសមស្របនិងរាល់គោលបំណង សមស្របទាំងអស់ដែលទាក់ទងជាមួយនឹងការប្រើប្រាស់និងការដាំដុះលើដីដ៏សមស្របដោយអ្នកជួល ។
៥. អ្នកជួលត្រូវធ្វើកសិដ្ឋាន ដាំដុះ ថែទាំ ដាក់ជី និងគ្រប់គ្រងកន្លែងដែលបានប្រគល់ជូនទាំងមូលបានល្អដូចម្ចាស់ ដោយយោងលើការអនុវត្តកសិកម្មល្អ ហើយមិនត្រូវអនុញ្ញាតឱ្យផ្នែកណាមួយនៃដី ឬដីទាំងមូលក្លាយជាសឹករិចរិល ខូចខាត ឬបាត់បង់គុណភាព និងផលិតភាព តាមរយៈការធ្វេសប្រហែស ឬការដាំដុះមិនសមស្រប និងត្រូវរក្សាឱ្យបានល្អស្អាតដូចដើម និងមិនមានការរាតត្បាតដោយស្មៅចង្រៃ ។
៦. អ្នកជួលនឹងត្រូវប្រគល់ (នៅចុងបញ្ចប់នៃការជួល) ដីទាំងអស់នៅក្នុងលក្ខណ្ឌនៃការដាំដុះ និងគ្រប់

គ្រងដូចដែលបានយល់ព្រមជាមួយកាតព្វកិច្ចរបស់អ្នកជួលក្រោមលក្ខ័ណ្ឌនៃការជួល ។

**មាត្រា៤២:**

ត្រូវមានការបញ្ជាក់រៀងរាល់លក្ខ័ណ្ឌនៃការជួលដោយម្ចាស់ជាមួយការអនុញ្ញាតពីអ្នកជួល ឬការទាមទាររបស់ម្ចាស់:

១. គ្រប់ពេលដែលសមស្រប ដើម្បីចូល (ទោះជាផ្ទាល់ខ្លួនឬដោយភ្នាក់ងារ) ទៅលើដីដែលបានជួលក្នុងគោលបំណងដើម្បីត្រួតពិនិត្យលក្ខ័ណ្ឌរបស់ដី និងសម្រាប់កែលំអដល់កន្លែងមានការខូះខាត ដែលនេះជាកាតព្វកិច្ចរបស់ម្ចាស់ត្រូវធ្វើ ប៉ុន្តែនៅក្នុងការងារនេះម្ចាស់នឹងមិនជ្រៀតជ្រែកដោយ មិនសមហេតុផលទៅលើអាជីព និងការប្រើប្រាស់ដីរបស់អ្នកជួលទេ ។

២. ដើម្បីលុបចោលការជួលបាន ដោយចេញប្រកាសបញ្ជាក់ពីគោលបំណងលុបចោលការជួលទៅឱ្យអ្នកជួល ចំពោះកន្លែងដែលជួល ឬការបង់ប្រាក់ដទៃទៀត ដែលមិនបានបងប្រាក់បីខែជាប់គ្នាតាមកាលកំណត់ ទោះបីជាតម្រូវឱ្យមានការសរសេរជាលាយលក្ខ័អក្សរ ដែលបានឯកភាពពីម្ចាស់ក៏ដោយ ឬអ្នកជួលមិនបានត្រួតពិនិត្យ ឬអនុវត្តរយ:ពេលបីខែជាប់គ្នាតាមលក្ខ័ណ្ឌនៃការជួល

៣. ដើម្បីចេញឬធានាថាបានចេញទៅឱ្យអ្នកជួល (នៅពេលដែលថ្លៃជួលត្រូវបានបង់) នូវវិក័យប័ត្រជាលាយលក្ខ័អក្សរសម្រាប់ការបង់ថ្លៃជួលនោះដោយអ្នកជួលឬដំណាងឱ្យអ្នកជួល

៤. មិនត្រូវបណ្តេញ ឬប៉ុនប៉ងដេញអ្នកជួលឬប្រកាសប្រាប់ឱ្យអ្នកជួលបិទឬបញ្ចប់ ឬប៉ុនប៉ងបញ្ចប់ការជួល លើលែងតែអ្វីដែលបានអនុញ្ញាត និងផ្តល់សិទ្ធដូចមានចែងនៅក្នុងបទប្បញ្ញត្តនៃច្បាប់នេះ

៥. ដើម្បីផ្តល់នូវការជូនដំណឹងសមហេតុផលដល់អ្នកជួល នូវបំណងចូលទៅលើដី ដើម្បីត្រួតពិនិត្យស្ថានភាព និងលក្ខ័ណ្ឌដី និងសម្រាប់ហេតុផលដែលសមស្របដ៏ទៃទៀតដែលពាក់ព័ន្ធជាមួយការប្រើប្រាស់ និង ការដាំដុះឱ្យបានត្រឹមត្រូវនៅលើដីដោយអ្នកជួល

៦. ដើម្បីអនុញ្ញាតឱ្យអ្នកជួល (ការបង់ថ្លៃឈ្នួលនិងកាអនុវត្តរបស់អ្នកជួលនូវលក្ខ័ណ្ឌទាំងឡាយ ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាជួល) កាន់កាប់និងរីករាយក្នុងកំឡុងពេលជួល ដោយមិនមានការរំខានពីម្ចាស់ ឬអ្នកតំណាងរបស់ម្ចាស់ដី

៧. នៅពេលបញ្ចប់កិច្ចសន្យា (អ្នកជួលប្រសិនបើអ្នកជួលបានបង់ថ្លៃឈ្នួលទាំងអស់ ហើយបានកាន់កាប់និងអនុវត្តតាមរាល់លក្ខ័ណ្ឌនៃការជួល) ត្រូវមានសិទ្ធដាំនិងប្រមូលផលដំណាំ ដែលនៅមាន និងទទួលសំណងសម្រាប់តម្លៃនៃការកែលំអរដែលមិនទាន់មានការខូចខាតដែលបានកសាងនៅលើដីដែលជាលទ្ធផលនៃការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធដែលបានធ្វើនៅក្រោមលក្ខ័ណ្ឌនៃកិច្ចសន្យាជួល

**មាត្រា៤៣:**

រាល់ជម្លោះដែលកើតមានឡើងនៅលើលក្ខ័ណ្ឌដែលបានបញ្ជាក់ក្នុងមាត្រា៣៥ ឬផ្នែកលើកំហុសឆ្គងក្នុងការបង់ថ្លៃឈ្នួលពន្ធឬថ្លៃបង់ចាំបាច់ផ្សេងៗទៀត ម្ចាស់ដីអាចអនុវត្តសកម្មភាពណាមួយដូចខាងក្រោមដើម្បីប្រឆាំងជាមួយអ្នកជួលៈ

១. ចេញប្រកាសផ្អែកលើការទាមទាររបស់អ្នកជួលដើម្បីឱ្យគេអាចដោះស្រាយជម្លោះ

២. បញ្ចប់កិច្ចសន្យាជួល មុនពេលចាប់ផ្តើមអនុវត្តសកម្មភាពណាមួយក្នុងផ្នែកនេះ ម្ចាស់ត្រូវពិចារណាៈ

 ១. ប្រភេទ និងទំហំនៃជម្លោះ ហើយថាតើវាអាចលើកលែងបានឬអត់

 ២. កាលៈទេសៈរបស់អ្នកជួល

 ៣. តើលក្ខ័ណ្ឌដែលធ្វើឱ្យមានជម្លោះនោះអាចដោះស្រាយបានដែរឬអត់ ដើម្បីដោះស្រាយនូវជម្លោះ

រាល់ករណីទាំងអស់មុនពេលម្ចាស់ចាប់ផ្តើមសកម្មភាពនៅក្នុងមាត្រានេះ ជាដំបូងម្ចាស់ត្រូវចេញនូវលិខិតព្រមានទៅដល់អ្នកជួលដោយណែនាំថាអ្នកជួលបានប្រព្រឹត្តល្មើសទៅនឹងលក្ខ័ណ្ឌនៃកិច្ចសន្យាជួលហើយបទល្មើសនោះត្រូវតែកែសម្រួល ហើយមិនអនុវត្តសកម្មភាពអ្វីទាំងអស់រហូតដល់រយៈពេលតិចជាងមួយខែគិតចាប់ពីថ្ងៃចេញលិខិតព្រមានបានកន្លងផុតទៅ។

នៅពេលដែលម្ចាស់សម្រេចចិត្តថាអនុវត្តសកម្មភាពមួយ ឬច្រើន ដោយយោងទៅលើមាត្រានេះ ម្ចាស់ត្រូវចេញប្រកាសទៅឱ្យអ្នកជួលដែលបានចោទប្រកាន់ថាបានប៉ុនប៉ងធ្វើឱ្យមានបទល្មើស ដែលបានដាក់ចេញនូវៈ

១. បទល្មើសដែលបានចោទប្រកាន់

២. វិធីសាស្ត្រដោះស្រាយដែលបានស្នើឡើង

៣. នៅកន្លែងមួយចំនួនដែលសកម្មភាពត្រូវការចំណាយពេលវេលា (ដែលមិនតិចជាងមួយខែ) នៅក្នុងរយៈពេលនេះគេត្រូវតែអនុវត្ត

៤. លំដាប់លំដោយនៃកំហុសមិនបានដោះស្រាយនូវបទល្មើសដែលបានចោទប្រកាន់

៥. សិទ្ធរបស់អ្នកជួលឡើងទៅតុលាការដើម្បីស្វែងរក ការបញ្ឈប់ភាពតានតឹងពីសកម្មភាពដែលម្ចាស់បាន និងកំពុងស្នើឡើង

នៅកន្លែងដែលអ្នកជួលមិនបានអនុវត្តតាមការប្រកាសដែលបានដាក់ចេញនៅក្នុងផ្នែកទីពខាងលើម្ចាស់អាចចេញប្រកាសដើម្បីលុបចោលកិច្ចសន្យាជួល។

ការប្រកាសលប់ចោលកិច្ចសន្យាជួលមិនត្រូវអនុវត្តភ្លាមទេ ដោយទុកឱ្យអ្នកជួលត្រូវធ្វើការផ្លាស់ទីកន្លែង ដែលពាក់ព័ន្ធមិនតិចជាងរយៈពេលមួយខែចាប់ពីថ្ងៃដែលបានចេញប្រកាស។

**មាត្រា៤៤ៈ**

ពាក្យសុំបញ្ឈប់កិច្ចសន្យាប្រឆាំងនឹងបទបញ្ជាលប់ចោលកិច្ចសន្យាអាចធ្វើដោយៈ

១. អ្នកជួល

២. ប្រសិនបើមនុស្សពីរឬច្រើននាក់មានសិទ្ធជួលនៅក្នុងកិច្ចសន្យាថាជាអ្នកកាន់កាប់រួមគ្នា ត្រូវធ្វើដោយ មនុស្សម្នាក់ឬច្រើននាក់តាងនាមឱ្យពួកគេ

៣. អ្នកជួលបន្តពីអ្នកជួលដំបូង

៤. អ្នកទទួលបញ្ចាំរបស់អ្នកជួល ឬអ្នកជួលបន្តរពីអ្នកជួល

**មាត្រា៤៥:**

ដោយពិចារណាថាតើផ្តល់ការបញ្ឈប់ឬអត់ ប្រឆាំងនឹងប្រកាសលុបចោលកិច្ចសន្យា តុលាការត្រូវចាត់ទុកបញ្ហាដូចខាងក្រោមដោយសារថាវាពាក់ព័ន្ធទៅនឹងករណីមុននេះគឺ:

១. តើផ្តល់អនុសាសន៍ជូនដល់ភាគីទាំងឡាយថាតើសកម្មភាពត្រូវបានពន្យាពេលដើម្បីអាចឱ្យភាគីទាំងឡាយចូលទៅក្នុងដំណើការនៃការសម្រុះសម្រួល និងការសម្រេចរបស់អាជ្ញាកណ្តាល ដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ទៅលើការយល់ព្រមដោះស្រាយដោយភាគីទាំងឡាយត្រូវតែយល់ព្រមដោយតុលាការ

២. ទំហំនៃជម្លោះ

៣. ភាពសមស្របនៃសកម្មភាពទាមទារឱ្យអនុវត្ត ឬឈប់អនុវត្តដោយអ្នកជួលដើម្បីដោះស្រាយជម្លោះ និងពេលវេលាដែលត្រូវអនុវត្តឬឈប់ដូចបានបញ្ជាក់នៅក្នុងប្រកាសរបស់ម្ចាស់នៅក្រោមមាត្រា៤២

៤. តើម្ចាស់តាំងចិត្តឱ្យមានវិវាទពីលក្ខ័ណ្ឌឬក៏អត់ ដែលម្ចាស់គឺស្ថិតនៅក្រោមការតព្វកិច្ចនៃកិច្ចសន្យាជួលដើម្បីប្រតិបត្តិតាមទំហំដែលវិវាទបានធ្វើឱ្យកើតមាននូវការខូចខាតដោយអ្នកជួល

៥. កម្រិតនៃការអត់ធ្មត់ដែលបានបង្ហាញដោយម្ចាស់ពាក់ព័ន្ធនឹងបទល្មើសនឹងលក្ខ័ណ្ឌផ្សេងទៀតដោយអ្នកជួល

៦. ទោះជាមានដំណោះស្រាយផ្សេង ដែលគេអាចអនុវត្តនៅក្នុងកាលៈទេសៈទាំងឡាយ

៧. ការចាប់អារម្មណ៍នៃភាគីទាំអស់ពាក់ព័ន្ធនឹងកិច្ចសន្យាជួល និង

៨. បញ្ហាដទៃទៀតដែលតុលាការគិតថាសមស្រប និងត្រឹមត្រូវ

តុលាការអាចចេញការប្រកាសបញ្ឈប់ប្រឆាំងនឹងការប្រតិបត្តិនៃបទបញ្ជាដូចដែលកាលៈទេសៈនៃករណីនោះទាមទារឱ្យធ្វើដូច្នោះ ។

**មាត្រា៤៦:**

រាល់បទល្មើសកើតមានឡើងក្នុងលក្ខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា៤១ អ្នកជួលអាចប្រកាសប្រាប់ម្ចាស់ថា ម្ចាស់បានល្មើសទៅនឹងលក្ខ័ណ្ឌនៃកិច្ចសន្យាជួលហើយស្នើឱ្យកែតម្រូវ ហើយបន្ទាប់មកមិនត្រូវធ្វើសកម្មភាពអ្វីទាំងអស់រហូតដល់ពេលវេលាតិចជាងមួយខែចាប់ពីថ្ងៃប្រកាសបានកន្លងផុតទៅ ។

ប្រសិនបើម្ចាស់មិនធ្វើសកម្មភាពអ្វីដើម្បីកែតម្រូវនូវបទល្មើសទេ ឬបន្តនូវបទល្មើសពីលក្ខ័ណ្ឌនៃកិច្ចសន្យាជួល អ្នកជួលអាចប្រកាសប្រាប់ម្ចាស់ថាអ្នកជួលនឹងស្វែងរកបទបញ្ជា ពីតុលាការដោយទាមទារឱ្យម្ចាស់អនុវត្តតាមកិច្ចសន្យាជួល ។

រាល់ករណីដែលអ្នកជួល ស្វែងរកបទបញ្ជាពីតុលាការដោយទាមទារឱ្យម្ចាស់អនុវត្តតាមលក្ខ័ណ្ឌនៃកិច្ចសន្យាជួល អ្នកជួលអាចស្វែងរកផងដែរនូវបទបញ្ជាពីតុលាការដែលថាម្ចាស់ត្រូវបង់ថ្លៃខូចខាតទៅឱ្យអ្នកជួល សម្រាប់ការបាត់បង់ចរិកា ផលលំបាក ដែលបណ្តាលមកពីកំហុសរបស់ម្ចាស់មិនបានអនុវត្តតាមលក្ខ័ណ្ឌនៃកិច្ចសន្យាជួល ។

## ជំពូកទី ៩
## ការបំលែងមកជាឬពីដីកសិកម្ម

### មាត្រា៤៧

ដី និងការប្រើប្រាស់ដីអនុវត្តសម្រាប់ជំពូកនេះ គឺជាដីឯកជន ឬដីដែលជួលពីនីតិ ឬរូបវ័ន្តបុគ្គល និងជា

- ដីកសិកម្មដូចដែលបានកំណត់ក្នុងច្បាប់នេះ
- ដីព្រៃដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីព្រៃឈើ
- ដីតំបន់ការពារដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីតំបន់ការពារ
- ការប្រើប្រាស់ដីសម្រាប់វិស័យជលផលដូចបានកំណត់ក្នុងច្បាប់ស្តីពីជលផល
- ដីការពារដែលស្ថិតនៅក្រោមច្បាប់បរិស្ថាន
- ដីដែលប្រើប្រាស់ស្ថិតនៅក្រោមការរៀបចំផែនការមេសម្រាប់ប្រើប្រាស់ដីដែលស្ថិតនៅក្រោមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- ដីដែលប្រើប្រាស់សម្រាប់គោលបំណងពិសេសដែលស្ថិតក្រោមច្បាប់ភូមិបាល ជាសម្បទានសេដ្ឋកិច្ច ឬសង្គមកិច្ច ។

### មាត្រា ៤៨:

មុនពេលចាប់ផ្តើមការងារបំលែងដីទៅជាឬពីដីកសិកម្ម(បន្ថែមទៅនឹងការអនុញ្ញាតឬអាជ្ញាប័ន ដែលគេតម្រូវ ពីនាយកដ្ឋានផ្សេងទៀតរបស់ក្រសួងកសិកម្ម ឬក្រសួងផ្សេងទៀតសម្រាប់អភិវឌ្ឍន៍ដីនោះ) ដែលគេត្រូវបំលែង អ្នកដែលបានស្នើឡើងនោះត្រូវដាក់ពាក្យទៅគណៈកម្មការបំលែងដីកសិកម្ម ដើម្បីសុំការអនុញ្ញាតបំលែងដីកសិកម្ម ។

### មាត្រា៤៩:

ត្រូវបង្កើតគណៈកម្មការបំលែងដីកសិកម្ម ។ ការរៀបចំ និងតួនាទីរបស់គណៈកម្មការនេះត្រូវកំណត់ដោយរាជរដ្ឋាភិបាល ហើយសមាជិករបស់គណៈកម្មការត្រូវជ្រើសរើស មកពីក្រសួងនិងស្ថាប័នដូចខាងក្រោម: ក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ល។

គណៈកម្មការនេះមានភារកិច្ចត្រូវ:

- កំណត់ និងវិនិច្ឆ័យនូវពាក្យស្នើសុំបំលែងទៅជាឬពីដីកសិកម្ម
- បង្កើតនូវគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីគ្រប់គ្រងនិងកំណត់នូវការបំលែងទៅជាឬពីដីកសិកម្ម
- អគ្គនាយកដ្ឋានកសិកម្មត្រូវជួយសម្របសម្រួលគណៈកម្មការនេះ ។

**មាត្រា៤០:**

ក្នុងការពិចារណាថាតើត្រូវផ្តល់ការអនុញ្ញាតការបំលែងដីឬអត់នោះ គណៈកម្មការបំលែងដីកសិកម្មត្រូវផ្អែកលើ:

១. ការប្រើប្រាស់ដីដែលដីនោះត្រូវដាក់ពាក្យសុំការអនុញ្ញាតឱ្យមានការបំលែង ចំនួនមនុស្សដែលធ្វើការ នៅលើដី និងតម្លៃដែលដីកំពុងតែផ្តល់ដល់សេដ្ឋកិច្ចជាតិដោយប្រៀបធៀបទៅនឹងការងារ និងតម្លៃសេដ្ឋកិច្ចដែលការស្នើឱ្យមានការផ្លាស់ប្តូរនោះអាចផ្តល់ជូន

២. កន្លែងដែលមានពាក្យស្នើសុំបំលែងដីកសិកម្មទៅជាដីផ្សេងមិនមែនជាដីកសិកម្ម។ គោលនយោបាយដីកសិកម្មជាតិ និងផែនការគ្រប់គ្រងដីកសិកម្មជាតិ និងគោលនយោបាយកសិកម្មផ្សេងៗទៀតដែលពាក់ព័ន្ធ

៣. កន្លែងដែលមានពាក្យសុំបំលែងដីព្រៃទៅជាដីកសិកម្ម។ គោលនយោបាយព្រៃឈើជាតិ និងផែនការគ្រប់គ្រងព្រៃឈើជាតិ

៤. កន្លែងដែលមានពាក្យសុំបំលែងដីដែលមិនប្រើប្រាស់ជាដីក្រុង ទៅជាដីប្រើប្រាស់សម្រាប់ជាដីក្រុង ។ ផែនការមេស្តីពីការប្រើប្រាស់ដីដែលបានរៀបចំក្រោមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលអាចអនុវត្តបានចំពោះដីដែលត្រូវដាក់ពាក្យសុំ

៥. សូចនាករដទៃទៀតកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្នុងការកំណត់ពាក្យស្នើសុំក្រោមមាត្រានេះ គណៈកម្មការនេះត្រូវផ្តល់:

១. ព័ត៌មានគ្រប់គ្រាន់ដល់បេក្ខជនពីពេលវេលា និងទីកន្លែងដែលពាក្យសុំនោះនិងត្រូវ បានគេពិចារណា

២. ឱកាសឱ្យបេក្ខជនគ្រប់គ្រាន់ដើម្បីបង្ហាញករណីនៃការបំលែងដី

៣. បុគ្គលទាំងអស់ដែលចាប់អារម្មណ៍ក្នុងការជំទាស់ទៅនឹងពាក្យស្នើសុំមានឱកាសនិងបង្ហាញពីករណីប្រឆាំងនឹងការបំលែងនោះ

៤. ហេតុផលពេញលេញសម្រាប់ធ្វើការសម្រេចចិត្ត

**មាត្រា៥១:**

គណៈកម្មការអាចផ្តល់ជូនឬបដិសេធការអនុញ្ញាតការបំលែងដី ហើយកន្លែងដែលអាចផ្តល់ការ អនុញ្ញាតបាននូវការបំលែងដី គណៈកម្មការអាចផ្តល់ដីទាំងមូលឬផ្នែកណាមួយ ដែលការអនុញ្ញាត នោះត្រូវបានអនុវត្ត និងការផ្តល់ជូនការបំលែងដីទាំងអស់អាចភ្ជាប់ជាមួយលក្ខ័ណ្ឌមួយចំនួនដូចមាននៅក្នុងគោលបំណងរបស់គោលការណ៍ណែនាំរាល់ការអភិវឌ្ឍដីក្រុងនៅលើដីដែលការអនុញ្ញាតការបំលែងដីអាចអនុវត្តទៅបានដើម្បីធានាថាដីដែលមិននៅក្នុងតំបន់ដែលផ្តល់ការអនុញ្ញាតឱ្យមានការបំលែងនោះ នឹងនៅតែត្រូវជាដីប្រើប្រាស់សម្រាប់កសិកម្ម ។

**មាត្រា៥២:**

ការចាប់ផ្តើមប្រើប្រាស់ ឬអភិវឌ្ឍនៅលើដីដែលពាក្យសុំការអនុញ្ញាតឱ្យមានការបំលែងដី ត្រូវបានដាក់ស្នើសុំ ប៉ុន្តែមិនទាន់បានទទួលការអនុញ្ញាត ឬត្រូវបានបដិសេធដោយគណៈកម្មការ គឺត្រូវចាត់ទុកថាជាការអភិវឌ្ឍខុសច្បាប់ ហើយត្រូវផ្តន្ទាទោសស្របទៅតាមជំពូកទី ១០ នៃច្បាប់នេះ ។

**មាត្រា៥៣:**

នីតិវិធីនិងយន្តការនៃដំណើរការដាក់ពាក្យស្នើសុំការអនុញ្ញាតការបំលែងដី និងការទទួលបាននូវការ អនុញ្ញាត ត្រូវកំណត់ដោយប្រកាស រីអនុក្រឹត្យ ។

## ជំពូកទី ១០
## បទល្មើស និងទោសប្បញ្ញត្តិ

**មាត្រា៥៤:**

រូបវន្តបុគ្គល-នីតិបុគ្គលដែលប្រព្រឹត្តល្មើសឬមិនបានអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬលិខិតបទដ្ឋានគតិយុត្តណាមួយក្រោមច្បាប់នេះ ដែលតម្រូវឱ្យធ្វើឬមិនធ្វើអ្វីមួយ ឬបទបញ្ជាដែលត្រឹមត្រូវតាមច្បាប់របស់មន្ត្រីមានសមត្ថកិច្ចដែលបានចេញទៅឱ្យរូបវន្តបុគ្គល-នីតិបុគ្គល នោះគឺជាកំហុស ថ្នាក់ទី៣ ។

រូបវន្តបុគ្គល-នីតិបុគ្គលដែលធ្វើឱ្យរាំងស្ទះដោយចេតនា ឬនៅពីក្រោយខណៈណាម្នាក់ឬមន្ត្រីណាមួយក្នុងការធ្វើឱ្យមានកំហុសឆ្គងដោយសារអំណាច ឬការអនុវត្តភារកិច្ចនៅក្រោមច្បាប់នេះគឺជាកំហុសថ្នាក់ទី៣។ ដំណើការរៀបចំឯកសារក្នុងការផាកពិន័យក្រោមច្បាប់នេះត្រូវធ្វើឡើងស្របតាម*ច្បាប់ស្តីពីទោសឧក្រិដ្ឋ*។

បែបបទនៃលិខិតចោទប្រកាន់ស្តីពីកំហុសក្រោមច្បាប់នេះត្រូវកំណត់ដោយប្រកាសរួមដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ ។

បុគ្គលល្មើសថ្នាក់ទី៣ក្រោមច្បាប់នេះ ត្រូវជាប់ពន្ធនាគារចាប់ពី មួយខែ រហូតដល់ មួយឆ្នាំ និងត្រូវផាកពិន័យចាប់ពី ១.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល ។

**មាត្រា៥៥:**

រូបវន្តបុគ្គល-នីតិបុគ្គលណាម្នាក់ដែលធ្វើខុសឆ្គង បណ្តាលឱ្យមានគ្រោះថ្នាក់ដល់មរតិកកសិកម្មជាតិ ឬ កេរ្សត្របរិស្ថាន ត្រូវបន្ថែមការផាកពិន័យសម្រាប់បង់ឱ្យការខូចខាត ដើម្បីស្តារ ឬជួសជុលនូវមរតិកកសិកម្មជាតិ ឬ ប្រព័ន្ធកេរ្សត្របរិស្ថានឡើងវិញឱ្យដូចលក្ខណ្ឌដើម ។

**មាត្រា៥៦:**

ជំនួសអោយការចោទប្រកាន់នូវរូបវន្តបុគ្គល-នីតិបុគ្គលណាម្នាក់ដែលប្រព្រឹត្តខុសឆ្គងក្រោមច្បាប់នេះ អគ្គនាយកដ្ឋានកសិកម្ម ជំនួសមុខឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចេញលិខិតព្រមានដល់អ្នកនោះ ។ លិខិតព្រមានត្រូវបានចុះបញ្ជីនៅក្នុងកំណត់ត្រារបស់អគ្គនាយកដ្ឋានកសិកម្ម ។

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**មាត្រា៥៧:**

នៅពេលដែលអ្នកទទួលប្រកាសស្ថិតនៅក្រោមច្បាប់នេះមិនអាចទទួលបានដោយផ្ទាល់ខ្លួន សេវាកម្មនៃសេចក្តីប្រកាស អាចត្រូវបានអនុវត្តតាមការបញ្ជាក់ទៅអ្នកពាក់ព័ន្ធពីខ្លឹមសារនៃប្រកាស ដោយផ្សព្វផ្សាយតាមរយៈសារព័ត៌មាន ឬវិទ្យុ ឬ

១. ផ្តល់សេចក្តីប្រកាសទៅឱ្យសមាជិកពេញវ័យនៃគ្រួសារដែលត្រូវទទួលដែលកំពុងស្នាក់នៅជាមួយ ឬ

២. ផ្តល់សេចក្តីប្រកាសទៅឱ្យភ្នាក់ងាររបស់អ្នកដែលត្រូវទទួលប្រកាស ឬ

៣. បិទភ្ជាប់សេចក្តីប្រកាសនៅកន្លែងសាធារណៈ ឬក្បែរលំនៅដ្ឋានរបស់អ្នកដែលត្រូវទទួល ។

**មាត្រា៥៨:**

មន្ត្រីដែលផ្តល់សិទ្ធដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវមានអំណាច ( ផ្តល់ការប្រកាសមុនមិនលើសពី ៤៨ម៉ោង) ដើម្បីចូលនិងត្រួតពិនិត្យគ្រប់ពេលវេលាដែលសមស្របនៅលើដី ( ក្រៅពីដីដែលកាន់កាប់ដាច់ដោយឡែកដូចជាផ្ទះ) ក្នុងគោលបំណងដែលជាប់ពាក់ព័ន្ធជាមួយការអនុវត្តច្បាប់នេះ ។

ចំពោះរាល់មន្ត្រីដែលបានផ្តល់សិទ្ធដើម្បីចូល ឬចុះត្រួតពិនិត្យដីក្រោមមាត្រានេះត្រូវនាំយកទៅជាមួយនូវលិខិតបញ្ជាក់នានា រឺលិខិតបញ្ជារបេសកកម្មដែលចុះហត្ថលេខាដោយអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ។

នៅពេលដែលមន្ត្រីដែលត្រូវបានផ្តល់សិទ្ធក្នុងមាត្រានេះ ធ្វើឱ្យខូចខាតទៅលើដី ឬរបស់របរផ្សេងទៀតនៅលើដីក្នុងកំឡុងពេលចូលត្រួតពិនិត្យ-បេសកកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មត្រូវចាត់មន្ត្រី ដើម្បីវាយតម្លៃការខូចខាតនោះ និងសងវិញភ្លាម ដោយផ្អែកលើការវាយតម្លៃនោះទៅដល់អ្នកដែលដី ឬរបស់របរនៅលើដីត្រូវបានធ្វើឱ្យខូចខាត ។

**មាត្រា៥៩:**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់ឱ្យឯកជនឬសហគមន៍ (រូបវន្តបុគ្គល-នីតិបុគ្គល) ដែលបានអនុវត្តនូវការប្រើប្រាស់ និងគ្រប់គ្រងដីកសិកម្មប្រកបដោយគុណភាពខ្ពស់ នូវគ្រឿងលើកទឹកចិត្ត ឬរង្វាន់មួយ ឬច្រើនដូចខាងក្រោម:

១. រង្វាន់ជាសាច់ប្រាក់

២. បណ្ណ័សរសើរ

៣. ជំនួយអភិវឌ្ឍន៍ដោយផ្ទាល់ទៅឱ្យសហគមន៍ និង

៤. ផ្សព្វផ្សាយជាសាធារណៈពីរង្វាន់សម្រាប់ការអនុវត្តបានល្អ

**មាត្រា៦០:**

អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ អាចត្រូវបានបង្កើតឡើងទៅលើបញ្ហាពាក់ព័ន្ធទាំងអស់ដែលមាននៅក្នុងច្បាប់នេះដើម្បីឱ្យមានប្រសិទ្ធភាពបន្ថែមទៀត និងប្រសើរឡើងទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា៦១:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រង និងរៀបចំការប្រើប្រាស់ដីកសិកម្ម លេខ ០៦ អនក ចុះថ្ងៃទី ៦ មេសា ឆ្នាំ ១៩៨៥ ត្រូវបញ្ចប់តាមរយៈច្បាប់នេះចាប់ពីច្បាប់នេះត្រូវបានអនុវត្ត ។

**មាត្រា៦២:**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

## ឧបសម្ព័ន្ធ

## និយមន័យ

ក្នុងច្បាប់នេះ ប្រសិនបើមិនមានបរិបទផ្សេងក្រៅពីនេះទេ ពាក្យខាងក្រោមនិងការពន្យល់អត្ថន័យ ដែលបានផ្តល់ទៅឱ្យពាក្យ-ឃ្លានៅក្នុងឧបសម្ព័ន្ធនោះគឺត្រូវបកស្រាយដូចខាងក្រោម:

"**រដ្ឋបាលកសិកម្ម**" មានន័យថាជាការធ្វើការសម្រេចចិត្ត ការអនុវត្តសកម្មភាព និងការធ្វើអ្វីផ្សេងៗទៀត ដែលមានគោលបំណងអនុវត្តនូវទិសដៅរបស់គោលនយោបាយកសិកម្មជាតិ និងអនុវត្តបទប្បញ្ញត្តិស្តីពីកសិកម្ម

"**កសិកម្ម**" មានន័យថាជាការដាំដុះនៃដី និងការប្រើប្រាស់ដី ដោយរួមបញ្ចូលទាំងសំណង់អាគារលើដី សម្រាប់គោលបំណង កសិកម្ម និងការដាំដុះ កំណត់ត្រាកសិកម្មប្រចាំថ្ងៃ និងការថែទាំ និងការបង្កាត់-ចិញ្ចឹមសត្វ ការប្រើប្រាស់ដីសម្រាប់ស្មៅចំណីសត្វ វាលស្មៅ ផ្សារសួន ឬថ្នាលបណ្តុះកូនរុក្ខជាតិ ដីចំការព្រៃ ការប្រើប្រាស់សម្រាប់ផលាវប្បកម្ម សម្រាប់ផលិតផលកសិកម្ម និងការកែច្នៃរាល់ផលិតផលកសិកម្ម។

"**ការកាន់កាប់កសិកម្ម**" មានន័យថាជាចំណែកនៃដីកសិកម្មមួយកន្លែង ដែលបទប្បញ្ញត្តិនៃច្បាប់នេះត្រូវបានអនុវត្ត។

"**ដីកសិកម្ម**" មានន័យថាជាដីទាំងអស់រួមទាំអាគារលើដី ទោះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬជារបស់បុគ្គល ឬជារបស់រួម និងប្រើប្រាស់ ឬស្នើឡើងដើម្បីប្រើប្រាស់ ឬត្រូវបានបែងចែកដោយគោលនយោបាយ ឬដោយផែនការដែលធ្វើឡើងក្រោមច្បាប់នេះឬផែនការមេប្រើប្រាស់ដីផ្សេងទៀត ដែលបានរៀបចំក្រោមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបណីយ៍កម្ម និងសំណង់សម្រាប់គោលបំណងកសិកម្ម ហើយរួមបញ្ចូលទាំងដីដែលបានផ្តល់ក្នុងរូបភាពជាដីសម្បទានសេដ្ឋកិច្ច ឬសង្គមកិច្ចក្រោមច្បាប់ភូមិបាលសម្រាប់ការប្រើប្រាស់កសិកម្ម ទោះជាដីនោះមិនប្រើសម្រាប់កសិកម្មក៏ដោយ ។

"**ផលិតផលកសិកម្ម**" រួមមាន:

១. ឬសទាំងអស់ រុក្ខជាតិ ស្មៅ គ្រាប់ បន្លែ ធញ្ញជាតិ ផ្លែឈើ និងសារធាតុសរសៃ

២. រាល់សម្ភារៈដាំដុះ និងគ្រាប់

៣. រុក្ខជាតិដ៏ទៃទៀត រុក្ខជាតិ ស្មៅ គ្រាប់ បន្លែ ធញ្ញជាតិ ផ្លែ សារធាតុសរសៃ សម្ភារៈ ឬផលិតផលផ្សេងទៀតដែលប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម។

"**ពាណិជ្ជកម្មផលិតកម្មកសិកម្ម**" រួមបញ្ចូលមុខរបរទាំងឡាយដែលទាក់ទងនឹងការផលិត លក់ និងទិញផលិតផលកសិកម្មដូចជា: ការដាំដុះដំណាំគ្រប់ប្រភេទ sericulture, arboriculture, វារីវប្បកម្ម ការចិញ្ចឹមសត្វ ការផលិតគ្រាប់ពូជដំណាំ ការបង្កាត់ពូជសត្វ ប្រភេទវារីសត្វ និងប្រភេទដំណាំ ការកែច្នៃផលិតផលកសិកម្ម ការទិញផលិតផលកសិកម្មតាមកិច្ចសន្យាដើម្បីផ្គត់ផ្គង់ទីផ្សារ សម្រាប់រោងចក្រកែច្នៃ ឬសម្រាប់នាំចេញ ។

"**កិច្ចសន្យាផលិតកម្មកសិកម្ម**" ជាកិច្ចព្រមព្រៀងពាក់ព័ន្ធពាណិជ្ជកម្មផលិតកម្មកសិកម្មធ្វើឡើងដោយភាគីពីរឬច្រើន ដែលសែបតាមផ្លូវច្បាប់ហើយបញ្ជាក់ជាមុននូវតម្រូវការដែលភាគីទាំងអស់ត្រូវគោរពតាម។

"**ផលិតកម្មកសិកម្មតាមកិច្ចសន្យា**" ជាផលិតកម្មដែលធានានូវតម្លៃ បរិមាណ គុណភាព និងលក្ខ័ណ្ឌទាំងឡាយរបស់ផលិតផលដែលបានព្រមព្រៀងមុនពេលផលិត។

"**អ្នកកាន់កាប់ដី**" មានន័ថាមនុស្សដែលកាន់កាប់និងប្រើប្រាស់ដី ដែលកំពុងធ្វើការងាកសិកម្ម ដោយអាស្រ័យនូវសិទ្ធធ្វើជាមុខរបរនៅលើដី ទោះជាសិទ្ធនោះបានមកដោយផ្ទាល់ឬមិនផ្ទាល់ តាមការស្នែងចេញ ឬតាម

ការពាក់ព័ន្ធពីច្បាប់ ឬជាលក្ខណៈច្បាប់ប្រពៃណីនិងទំនៀមទំលាប់ និងរួមបញ្ចូលការកាន់កាប់ដីដោយហេតុផលបុគ្គល ឬរួម ឬអ្នកជួលនៃម្ចាស់តែមួយឬរបស់រដ្ឋ ។

"**ការថែរក្សាដី** " មានន័យថាវិធីសាស្ត្រជាយុទ្ធសាស្ត្រទៅលើបញ្ហាការអភិរក្សធនធានដី ដែលទាក់ទងនឹងកិច្ចសហការក្នុងកម្រិតរួមច្រើនជាងកម្រិតទ្រព្យសម្បត្តិបុគ្គល ដែលគ្រប់សហគមន៏ធ្វើសកម្មភាពប្រមូលផ្តុំដើម្បីអភិរក្ស និងកែលំអគុណភាពដីកសិកម្ម ។

"**ការអនុញ្ញាតការបំលែងដី**" មានន័យថាជាការអនុញ្ញាតឱ្យបំលែងដីកសិកម្មទៅប្រើប្រាស់ក្នុងវិស័យផ្សេង

" **កិច្ចសន្យាជួល**" មានន័យថាកិច្ចសន្យាគ្រប់ប្រភេទ (ស្តែងចេញ ឬបញ្ជាក់ ឬសន្មត ដែលមាននៅក្នុងច្បាប់នេះ) ដែលបង្កើតកិច្ចសន្យាជួលដីកសិកម្ម ឬការស្រុះស្រួលគ្នាណាមួយដែលបង្កើតនូវសិទ្ធដើម្បីដាំដុះ ឬប្រើប្រាស់ដីកសិកម្ម និងរួមបញ្ចូលទាំងការជួលបន្ត ។

"**អ្នកជួល**" មានន័យថាជាមនុស្សដែលកិច្ចសន្យាជួលត្រូវបានផ្តល់ជូន និងរួមបញ្ចូលមនុស្សដែលបានទទួលយកការ ផ្ទេរ ឬការងារនៃកិច្ចសន្យាជួល និងការជួលបន្តរ

"**ម្ចាស់**" មានន័យថាជាមនុស្សដែលផ្តល់កិច្ចសន្យាជួលទ្រព្យសម្បត្តិដែលមិនអាចផ្លាស់ទីបាន (និងអ្នកដែលអាច ឬមិនអាចជាម្ចាស់នៃទ្រព្យសម្បត្តិ) និងជាអ្នកដែលត្រូវមានសិទ្ធទទួលថ្លៃឈ្នួល និងប្រាក់ចំណេញពីដីកសិកម្ម និងរួមបញ្ចូលទាំងអ្នកតំណាងផ្ទាល់ខ្លួន អ្នកអនុវត្តន៏ អ្នកចាត់ការ និងមនុស្សណាមួយដែលអាចជាម្ចាស់ និងរួមទាំងម្ចាស់បន្ទាប់ ។

" **មរតិកកសិកម្មជាតិ** " មានន័យថាជាផលិតផលកសិកម្មជាតិនៃផែនដី រួមបញ្ចូលទាំងដី គ្រាប់រុក្ខជាតិ ដំណាំ ដើមឈើ ដែលមាននៅក្នុងប្រទេសកម្ពុជា និងមានដើមកំណើតនៅកម្ពុជា ដែលអាចឱ្យគេតាមដានពីអតីតកាលជាច្រើនសតវត្សបាន ហើយដែលផ្តល់ប្រព័ន្ធជីវៈចម្រុះជាច្រើនប្រភេទ និងពិសេសសម្រាប់កម្ពុជា ។

" **មន្ត្រី**" មានន័យថាជាមន្ត្រីសមត្ថកិច្ចអគ្គនាយកដ្ឋានកសិកម្ម រឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

"**មនុស្ស**" រួមមានរូបវ័ន្តបុគ្គល និង នីតិបុគ្គល

"**ការអនុវត្តកសិកម្មល្អ**" ទាក់ទងនឹងដីកសិកម្មគឺដីនឹងត្រូវបានគេប្រើប្រាស់ ដាំដុះ និងគ្រប់គ្រងក្នុងន័យមួយដែលបានគិតគូរដើម្បីធានាបមាណើល្អប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពផលិតកម្ម ។

"**ភាគីផលិត**" គឺជានីតិ ឬរូបវ័ន្តបុគ្គលដែលមានមុខរបរខាងផលិតកម្មកសិកម្ម

"**ភាគីទិញ**" គឺជានីតិ ឬរូបវ័ន្តបុគ្គលដែលធ្វើពាណិជ្ជកម្មកសិកម្មស្របច្បាប់ ហើយប្រតិបត្តិតាមដំណើការដែលបានទាមទារ ។

" **វិក័យបត្រ** " មានន័យថាជាកំណត់សំគាល់ទាំងឡាយអាចជា អនុសារណះ ឬការសរសេរអ្វីៗទាំងអស់ដែលថ្លៃឈ្នួលត្រូវបានទទួលស្គាល់ ឬប្រាប់ថាបានទទួល ឬកក់ ឬបង់ ឬបំណុល ឬការទាមទារ ឬផ្នែកណាមួយនៃបំណុល ឬការទាមទារថ្លៃឈ្នួល ត្រូវបានទទួលស្គាល់ ចុះហត្ថលេខា ឬបញ្ចូលការទទួលស្គាល់ទាំងនោះ ដើម្បីឱ្យ

គេសងដោយពេញចិត្ត ឬបានបន្ទូបន្ថយ (ឬដែលប្រកាស ឬបញ្ចូលការទទួលស្គាល់នោះ) ត្រូវបានចុះហត្ថលេខាដោយ ឬជំនួសដោយម្ចាស់ និងរៀបរាប់ពីដីដែលថ្លៃឈ្នួលទាក់ទងយ៉ាងសំខាន់ដើម្បីអាចឱ្យគេកំណត់បាន ។

" **ដី** " មានន័យថាជាប្រព័ន្ធចលករ-ឌីណាមិចដោយធម្មជាតិនៃសារធាតុរ៉ែដែលមិនរឹងមាំ និងសារធាតុសរីរាង្គនៅលើសំបកផែនដី

" **ការអភិរក្សដី**" រួមបញ្ចូលទាំងដំណើការបច្ចេកទេស និងមិនបច្ចេកទេស ដែលគេអនុវត្តទៅលើដី ដើម្បីធានាថាដីរួមទាំងប្រព័ន្ធអេកូឡូស៊ីត្រូវបានអភិរក្ស

" **ឱនភាពដី** " រួមបញ្ចូលការសឹករិចរិលទាំងកត្តារូប គីមី និងជីវ ដែលអាចធ្វើឱ្យបាត់បង់សារធាតុសរីរាង្គធ្វើឱ្យថយចុះ ជីជាតិដី ទម្រង់ដី ការហូរច្រោះដី ធ្វើឱ្យមានការប្រែប្រួលជាអវិជ្ជមាន ដូចជាកើនឡើងជាតិអំបិលជាតិអាស៊ីត ឬជាតិអាល់កាឡាំង និងផលប៉ះពាល់នៃជាតិពុលគីមី ភាពកខ្វក់ ឬទឹកលិចហួសហេតុ

"**គុណភាពដី**" មានន័យថាជាសមត្ថភាពនៃមុខងាររបស់ប្រភេទដីសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី ធម្មជាតិ ឬសិប្បនិម្មិត ឬកម្រិតការប្រើប្រាស់ដីដើម្បីធានានិរន្តរភាពផលិតភាពរុក្ខជាតិឬសត្វ រក្សាឬពង្រឹងគុណភាពខ្យល់ និងទឹក និងគាំទ្រសុខភាពរបស់មនុស្សនិងជម្រកសត្វ

"**ការលុបចោល**" ទាក់ទងនឹងកិច្ចសន្យាជួល មានន័យថាជាការបញ្ចប់ការជួលដោយហេតុផលថាកិច្ចសន្យាជួលនោះឈានទៅដល់ចុងបញ្ចប់នៃកិច្ចព្រមព្រាងរបស់វា ឬមកពីហេតុផលផ្សេងៗទៀត

"**ការប្រើប្រាស់ជាដីក្រុង**" មានន័យថាការប្រើប្រាស់ដីសម្រាប់គោលបំណងផ្សេងៗដែលទាមទារឱ្យមានការអនុញ្ញាតសាងសង់ស្ថិតនៅក្រោមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបណីយកម្ម និងសំណង់ និងការប្រើប្រាស់ផ្សេងទៀត ឬការអភិវឌ្ឍដី ដែលធ្វើឱ្យការប្រើប្រាស់ដីកសិកម្មមិនអាចអនុវត្តទៅបាននៅកន្លែងនោះទៀត ។